គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ៍ ភីអិលស៊ី
NIRON MICROFINANCE PLC.

របាយការណ៍ប្រចាំឆ្នាំ
២០២៣

niron.com.kh

មាតិកា

ប្រវត្តិសំខាន់ៗ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី	០១
បណ្តាញការិយាល័យប្រតិបត្តិការ	០៣
ទស្សនវិស័យ និងបេសកកម្ម	០៤
លទ្ធផលសង្ខេបផ្នែកហិរញ្ញវត្ថុ	០៥
លទ្ធផលសង្ខេបផ្នែកប្រតិបត្តិការ	០៦
ចំណាប់អារម្មណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល	០៧
រចនាសម្ព័ន្ធគ្រប់គ្រង	០៩
សមាសភាពក្រុមប្រឹក្សាភិបាល	១០
សមាសភាពគណៈគ្រប់គ្រង	១២





អំពី

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និវន្តរ ភីអិលស៊ី

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និវន្តរ ភីអិលស៊ី គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួល អាជ្ញាប័ណ្ណប្រកបអាជីវកម្មជាផ្លូវការនៅថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០១៤ ពីសំណាក់ធនាគារជាតិនៃកម្ពុជា។ ត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និវន្តរ ភីអិលស៊ី មានការិយាល័យចំនួន ១១ នៅតាមបណ្តាស្រុក-ខេត្ត-ក្រុង-រាជធានី (ការិយាល័យកណ្តាល ០១ និងសាខាចំនួន ១០) និងមានបុគ្គលិកសរុប ១៩១នាក់។ ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និវន្តរ ភីអិលស៊ី មានអតិថិជនសកម្មចំនួន ៥.១០០នាក់ និងទំហំឥណទានដុលសរុបចំនួនជាង ២,៤៤ លានដុល្លារអាមេរិក ជាមួយនឹងកម្រិតឥណទានមានហានិភ័យ (PAR) ទាប។

សាខារបស់គ្រឹះស្ថាន	បុគ្គលិកបម្រើការងារ	អតិថិជនខ្ចីប្រាក់	ទំហំឥណទានដុលសរុប



១១ ការិយាល័យ	១៩១ នាក់	៥.១០០ នាក់	២,៤៤ លានដុល្លារ អាមេរិក

ការវិវឌ្ឍន៍របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ កីអិលស៊ី

២០០៨

២០០៨

បង្កើត និងដំណើរការដំបូងជា អង្គការហិរញ្ញវត្ថុ "និរន្តរទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ច សហគមន៍" នៅថ្ងៃទី០៨ខែសីហា ឆ្នាំ២០០៨

២០០៩

២០០៩

ចុះបញ្ជីជាអង្គការមិនមែនរដ្ឋាភិបាល ដោយអនុលោមតាមច្បាប់សមាគម និងច្បាប់ការងារ ដែលទទួលស្គាល់ដោយក្រសួងមហាផ្ទៃ

២០១៣

២០១៣

និរន្តរទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍បានវិវឌ្ឍខ្លួនជានិរន្តរគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ កីអិលស៊ី ដែលជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ដែលទទួលអាជ្ញាប័ណ្ណ ពីធនាគារជាតិនៃកម្ពុជា

២០១៥

២០១៥

ច្របាច់ចូលគ្នាជាមួយអង្គការក្រៅ រដ្ឋាភិបាល ក្នុងស្រុកមួយរួចប្តូរនាមករណ៍ជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ កីអិលស៊ី

២០១៦

២០១៦

គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ និរន្តរកីអិលស៊ី មានបណ្តាញប្រតិបត្តិការចំនួន ៥៥ សាខា គ្របដណ្តប់លើ ២៤ ខេត្ត-ក្រុង ក្នុងព្រះរាជាណាចក្រកម្ពុជា ជាមួយបុគ្គលិកបម្រើការងារចំនួន ១.០១៨នាក់

២០១៩

២០១៩

ក្នុងឆ្នាំនេះប្រតិបត្តិការ បណ្តាសាខារបស់គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ និរន្តរ បានកើនឡើង បើធៀបនិងផែនការដែលដាក់ចេញ, លទ្ធភាពក្នុងការស្វែងរកប្រាក់ចំណេញបានមានភាពល្អប្រសើរជាងមុន

២០២១

២០២១

នៅក្នុងសម័យកូវីដ-១៩ គ្រឹះស្ថានបានសម្របខ្លួនក្នុងបរិបទគន្លងបែបថ្មី និងបានដាក់ចេញនូវយុទ្ធសាស្ត្រផ្សេងៗ ដើម្បីធានាអោយបាននូវស្ថេរភាព

២០២២

២០២២

បានសហការជាមួយនិងភ្នាក់ងារវឹង និងទ្រូម៉ាន់នី ក្នុងគោលបំណងផ្តល់ភាពងាយស្រួលជូនទៅដល់អតិថិជនទាំងអស់ក្នុងការទូទាត់ប្រាក់ត្រឡប់មកគ្រឹះស្ថានវិញ។

២០២៣

២០២៣

គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ និរន្តរកីអិលស៊ី មានការិយាល័យកណ្តាលនៅរាជធានីភ្នំពេញ និងបណ្តាញប្រតិបត្តិការចំនួន ១០ សាខា ក្នុងព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងបុគ្គលិកបម្រើការងារ ១៩១នាក់ ។



តំបន់ប្រតិបត្តិការរបស់ និរន្តរ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣,និរន្តរ មានបណ្តាញការិយាល័យទូទាំងប្រទេសដូចខាងក្រោម៖

ល.រ	ការិយាល័យ/សាខា	អាសយដ្ឋាន
១	ការិយាល័យកណ្តាល	អគារលេខ ២១, ២៣, ២៥ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី, ខណ្ឌសែនសុខ, រាជធានីភ្នំពេញ
២	សាខាក្រុងព្រះសីហនុ	ផ្លូវលេខ៧០១អា, ភូមិ៣, សង្កាត់លេខ១, ក្រុងព្រះសីហនុ, ខេត្តព្រះសីហនុ
៣	សាខាស្រុកព្រៃនប់	ផ្លូវជាតិលេខ៤, ភូមិសំរុងក្រោម, ឃុំសំរុង, ស្រុកព្រៃនប់, ខេត្តព្រះសីហនុ
៤	សាខាស្រុកស្រែអំបិល	ភូមិត្រពាំង, ឃុំស្រែអំបិល, ស្រុកស្រែអំបិល, ខេត្តកោះកុង
៥	សាខាស្រុកបុទុមសាគរ	ភូមិថ្មស, ឃុំថ្មស, ស្រុកបុទុមសាគរ, ខេត្តកោះកុង
៦	សាខាស្រុកខ្សាច់កណ្តាល	ភូមិក្នុង, ឃុំព្រែកតាមាក់, ស្រុកខ្សាច់កណ្តាល, ខេត្តកណ្តាល
៧	សាខាក្រុងកំពង់ចាម	ផ្លូវជាតិលេខ៧, ភូមិទី៦, សង្កាត់វាលវង់, ក្រុងកំពង់ចាម, ខេត្តកំពង់ចាម
៨	សាខាខេត្តកំពង់ស្ពឺ	ផ្លូវជាតិលេខ៤, ភូមិព្រៃស្លឹក, សង្កាត់ច្បារមន, ក្រុងច្បារមន, ខេត្តកំពង់ស្ពឺ
៩	សាខាក្រុងសៀមរាប	ភូមិគ្រួស, សង្កាត់ស្វាយដង្គំ, ក្រុងសៀមរាប, ខេត្តសៀមរាប
១០	សាខាស្រុកអន្លង់វែង	ផ្លូវលេខ៦៧, ភូមិថ្នល់កែង, ឃុំអន្លង់វែង, ស្រុកអន្លង់វែង, ខេត្តឧត្តរមានជ័យ
១១	សាខាស្រុកសូទ្រនិគម	ភូមិបន្ទាយស្រី, ឃុំជុំដៃក, ស្រុកសូទ្រនិគម, ខេត្តសៀមរាប



ទស្សនវិស័យ និង បេសកកម្ម


ទស្សនវិស័យ

"គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី នឹងក្លាយជាគ្រឹះស្ថានផ្តល់សេវាហិរញ្ញវត្ថុយ៉ាងទូលំទូលាយ ប្រកបដោយការអភិវឌ្ឍ និងគុណធម៌"។


បេសកកម្ម

"គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី គឺជាគ្រឹះស្ថានដែលផ្តល់សេវាហិរញ្ញវត្ថុដ៏ សម្បូរបែបដល់ប្រជាពលរដ្ឋដោយផ្តោតជាអាទិភាពលើ៖ ផ្តល់ភាពងាយស្រួលដល់អតិថិជន ក្នុងការទំនាក់ទំនងប្រើប្រាស់ សេវាហិរញ្ញវត្ថុ, បង្កើនភាពស្និទ្ធស្នាលនិងជាដៃគូដ៏ល្អ ដើម្បីឈានទៅរកភាពរីកចម្រើនទាំងអស់គ្នា, កសាងសមត្ថភាពបុគ្គលិក ពង្រីកបណ្តាញប្រតិបត្តិការអោយបានធំទូលាយ រួមជាមួយនឹងការអភិវឌ្ឍផលិតផល និងបច្ចេកវិទ្យាទំនើបទាន់សម័យ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ ច្បាប់ សីលធម៌ បរិស្ថាន និងកិច្ចការសង្គម"។


លទ្ធផលសង្ខេបហិរញ្ញវត្ថុ




១.ទ្រព្យសកម្ម គិតជាពាន់រៀល




២.បំណុលគិតជាពាន់រៀល




៣.មូលនិធិទ្រព្យម្ចាស់ គិតជាពាន់រៀល




៤.ឥណទានដុល គិតជាពាន់រៀល




៥.ដើមទុន គិតជាពាន់រៀល



៦.ចំណូលដុល គិតជាពាន់រៀល



៧.ចំណេញមុនពេលដកពន្ធ គិតជាពាន់រៀល



៨.ចំណេញសុទ្ធក្រោយដកពន្ធ គិតជាពាន់រៀល



លទ្ធផលសង្ខេប
ផ្នែកប្រតិបត្តិការ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣
ចំនួនការិយាល័យសរុប	១១
ចំនួនបុគ្គលិកសរុប	១៩១
ប្រុស	១៥៤
ស្រី	៣៧
មន្ត្រីឥណទាន ធៀបនឹងបុគ្គលិកសរុប	៣៨,២២%
ចំនួនអតិថិជនសរុប	៥.១០០
ទំហំឥណទានដុលសរុប (ដុល្លារអាមេរិក)	២.៤៣៨.៦២១
ចំនួនអតិថិជនកម្ចី ធៀបនឹងមធ្យមភាគមន្ត្រីឥណទាន	៧០
សមតុល្យប្រាក់កម្ចី ធៀបនឹងមធ្យមភាគមន្ត្រីឥណទាន	៣៣.៤០៦
សមតុល្យប្រាក់កម្ចី ធៀបនឹងមធ្យមភាគអតិថិជន	៤៧៨



លោក ឃុន ស្រ៊ា

ប្រធានក្រុមប្រឹក្សាភិបាល

ចំណាប់អារម្មណ៍ របស់ ប្រធានក្រុមប្រឹក្សាភិបាល

ក្នុងឆ្នាំ២០២៣ ជាឆ្នាំប្រកដដោយភាពរាំងស្ទះ និងភាពមិនច្បាស់លាស់ជាសកល ប៉ុន្តែក៏បានរំលេចផងដែរ នូវស្ថេរភាព ដ៏រឹងមាំក្នុងសេដ្ឋកិច្ចកម្ពុជានិងក្នុងប្រតិបត្តិការរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ កីអិលស៊ី។ដំណាក់កាលក្រោយជំងឺរាតត្បាត សាកលកូវីត-១៩ សង្គ្រាមរុស្សី-អ៊ុយក្រែន ឧបសគ្គខ្សែសង្វាក់ផ្គត់ផ្គង់សកល និងសម្ពាធអតិផរណា សុទ្ធតែជាបញ្ហាប្រឈមជា ច្រើនដល់សេដ្ឋកិច្ច ទូទាំងសកលលោក ។ ទោះបីជាយ៉ាងណាក៏សេដ្ឋកិច្ចប្រទេសកម្ពុជា បង្ហាញនូវស្ថេរភាពរឹងមាំ គួរឲ្យកត់ សម្គាល់ ។

ទោះបីជាមានបញ្ហាប្រឈមនេះក៏ដោយ ក៏គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ កីអិលស៊ី នៅតែមានភាពរឹងមាំ និងបន្តធ្វើ ប្រតិបត្តិការអាជីវកម្មរបស់ខ្លួនដោយការប្រុងប្រយ័ត្ន,ការខិតខំប្រឹងប្រែងដាក់យុទ្ធសាស្ត្រថ្មីៗ ការប្តេជ្ញាចិត្ត អភិវឌ្ឍន៍ផលិតផល រក្សាបាននូវកំណើនឥណទានប្រកបដោយគុណភាព និងការគ្រប់គ្រងផ្ទៃក្នុងដ៏រឹងមាំ។ជាមួយគ្នានេះដែរ និរន្តរ ក៏សម្រេចបាននៅ លទ្ធផលអាជីវកម្មដ៏ល្អប្រសើរក្នុងឆ្នាំ ២០២៣ មានដូចខាងក្រោម៖

- ចំនួនអតិថិជន សម្រេចបានត្រឹម : ៥,១០០ នាក់
- ឥណទាន សម្រេចបានត្រឹម : ២,៤៣៨,៦២១ ដុល្លារអាមេរិក

ទោះបីជាឆ្នាំ២០២៣ កន្លងមកនេះ យើងពុំអាចអនុវត្តតាមផែនការដែលបានកំណត់ ១០០% ក៏ពិតមែន ប៉ុន្តែលទ្ធផលហិរញ្ញវត្ថុ យើងបានបង្ហាញពីភាពសមស្របនៃយុទ្ធសាស្ត្រ ភាពទាក់ទាញនៃផលិតផល និងការផ្តល់សេវាកម្មរបស់យើងព្រមទាំងកិច្ចខិតខំ ប្រឹងប្រែងធ្វើការ និងការសហការនៅក្នុងក្រុមការងាររបស់គ្រឹះស្ថានផងដែរ។


គោលដៅហិរញ្ញវត្ថុ



Net Income
១០៧.៣៨០
ដុល្លារអាមេរិច

Loan Outstanding
២.៩០៣.២៣៣
ដុល្លារអាមេរិច






NPL Ratio
៦,៤៧%

WO.Collection
១០៣.៣១៣
ដុល្លារអាមេរិច



យុទ្ធសាស្ត្រគន្លឹះ



បង្វែរគោលដៅ យុទ្ធសាស្ត្រ ពីបរិមាណ ឥណទានមកជាប្រាក់ ចំណេញ

ជំរុញយុទ្ធសាស្ត្រស្វែងរកប្រាក់ចំណេញតាមរយៈ ការលើក ទឹកចិត្តដល់ប្រតិបត្តិការ

ជំរុញការប្រមូលបំណុលលុបចេញពីបញ្ជីឱ្យ អស់ពីលទ្ធភាព


បន្តពង្រឹង និងកែលម្អការងាររបស់នាយកដ្ឋាន ឥណទានដែលជានាយកដ្ឋានស្នូល របស់ គ្រឹះស្ថាន

បន្តស្វែងរកឱកាស វិនិយោគ និងបង្កើត អាជីវកម្មថ្មីៗបន្ថែម

តាំងនាមក្រុមប្រឹក្សាភិបាល ខ្ញុំសូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅចំពោះ រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជា អាជ្ញាធរគ្រប់លំដាប់ថ្នាក់ អតិថិជន ព្រមទាំងកម្មករនិយោជិតគ្រប់លំដាប់ថ្នាក់ ក្រុមប្រឹក្សាភិបាល និងភាគទុនិក ដែលតែងតែជួយគាំទ្រទាំងកម្លាំងកាយ កម្លាំងចិត្ត និងសហការយ៉ាងពេញទំហឹងតាំងពីដើមរៀងមក ធ្វើឱ្យគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី ទទួលបានជោគជ័យ និងរីកចម្រើនជាបន្តបន្ទាប់រហូតមកដល់បច្ចុប្បន្ននេះ។

ជាទីបញ្ចប់ ខ្ញុំសូមគោរពជូនដល់សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក-លោកស្រី អ្នកនាងកញ្ញា និងកម្មករនិយោជិតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី គ្រប់លំដាប់ថ្នាក់ សូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លៀតឡើយ។

រចនាសម្ព័ន្ធគ្រប់គ្រង



សមាសភាពក្រុមប្រឹក្សាភិបាល



លោក ឃុន ស្រ៊ា

ប្រធានក្រុមប្រឹក្សាភិបាល

សញ្ជាតិខ្មែរ កើតនៅឆ្នាំ ១៩៥៣ ។លោកធ្លាប់បានចូលរួមវគ្គហ្វឹកហ្វឺនជាច្រើនទាក់ទងនឹងការគ្រប់គ្រង ចាត់ចែងអាជីវកម្ម។ បច្ចុប្បន្នលោកមាននាទីជាអ្នកចាត់ចែងជាន់ខ្ពស់នៅក្នុង ក្រុមហ៊ុនប្រេងឥន្ធនៈមួយ ។មុនពេលតែងតាំងជា ប្រធានក្រុមប្រឹក្សាភិបាល លោកគឺជាស្ថាបនិកម្នាក់ និង ជាសមាជិកក្រុមប្រឹក្សាភិបាលរបស់និរន្តរ ចាប់តាំងពីបង្កើតក្នុងឆ្នាំ២០១៣ មក។



លោក ឃុន ស៊ីណា

អភិបាល

សញ្ជាតិខ្មែរ កើតនៅឆ្នាំ ១៩៨៣ ។ លោកបានទទួលសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ពី សាកលវិទ្យាល័យ បៀលប្រាយ ជំនាញគ្រប់គ្រងទូទៅនៅឆ្នាំ២០១១និងធ្លាប់បានចូលរួមវគ្គហ្វឹកហ្វឺនជាច្រើន ទាក់ទងនឹងការគ្រប់គ្រង មីក្រូហិរញ្ញវត្ថុ។ លោកគឺជាស្ថាបនិកម្នាក់របស់និរន្តរ ចាប់តាំងពីបង្កើតនៅក្នុងឆ្នាំ២០១៣ មក។ មុនពេលតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាល និងប្រធាននាយកប្រតិបត្តិ លោកធ្លាប់មាន បទពិសោធន៍ ជាមន្ត្រីឥណទាន ជាគណនេយ្យករ នាយកនាយកដ្ឋានហិរញ្ញវត្ថុ និងប្រធាននាយកហិរញ្ញវត្ថុ។



លោក ហ៊ីង កុលសំណាង

អភិបាលឯករាជ្យ

សញ្ជាតិខ្មែរ កើតនៅឆ្នាំ១៩៧៦ លោកទទួលបានបរិញ្ញាបត្រជំនាញវិស្វកម្មកសិកម្ម។ លោកធ្លាប់បានចូលរួមវគ្គហ្វឹកហ្វឺន ជាច្រើនទាក់ទងនឹងការគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ។ លោកត្រូវបានតែងតាំងជាក្រុមប្រឹក្សាភិបាលឯករាជ្យរបស់ និរន្តរនៅឆ្នាំ២០២២។ មុនពេលតែងតាំងជា ក្រុមប្រឹក្សាភិបាលឯករាជ្យ លោកធ្លាប់មានបទពិសោធន៍ជា៖ ប្រធាននាយកដ្ឋានប្រតិបត្តិការ ប្រធាននាយកប្រតិបត្តិការទីប្រឹក្សា អគ្គនាយក និងជាម្ចាស់កោជនីយដ្ឋាន។



លោក ឈុន ស៊ីណា

ប្រធាននាយកប្រតិបត្តិ

សញ្ជាតិខ្មែរ កើតនៅឆ្នាំ ១៩៨៣ លោកបានទទួលសញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ពីសាកលវិទ្យាល័យបៀលប្រាយ ជំនាញគ្រប់គ្រងទូទៅនៅឆ្នាំ២០១១ និងធ្លាប់បានចូលរួមវគ្គហ្វឹកហ្វឺនជាច្រើន ទាក់ទងនឹងការគ្រប់គ្រង មីក្រូហិរញ្ញវត្ថុ។ លោកគឺជាស្ថាបនិកម្នាក់របស់និរន្តរ ចាប់តាំងពីឡើតនៅក្នុងឆ្នាំ២០១៣ មក។ មុនពេលតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាល និងប្រធាននាយកប្រតិបត្តិ លោកធ្លាប់មានបទពិសោធន៍ជា មន្ត្រីឥណទាន ជាគណនេយ្យករ នាយកនាយកដ្ឋានហិរញ្ញវត្ថុ និងប្រធាននាយកហិរញ្ញវត្ថុ។



លោក មាស វ៉ាន់ដេត

(នាយកនាយកដ្ឋានព័ត៌មានវិទ្យា)

សញ្ជាតិខ្មែរ កើតនៅឆ្នាំ១៩៧៤ លោកទទួលសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ជំនាញ បច្ចេកវិទ្យាព័ត៌មាននៅ ឆ្នាំ២០០៧ និង ធ្លាប់បានចូលរួមវគ្គហ្វឹកហ្វឺនជាច្រើន ទាក់ទងនឹងការគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ។ ក្រៅពីបម្រើការងារជាមួយនិរន្តរ លោកក៏ជាសាស្ត្រាចារ្យផ្នែកព័ត៌មានវិទ្យាមួយរូប នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញផងដែរ។



លោក កៀត វីរៈ

(ប្រធានមុខងារប្រតិបត្តិតាម)

សញ្ជាតិខ្មែរ កើតនៅឆ្នាំ១៩៨២ លោកបានទទួលសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ពីសាកលវិទ្យាល័យ បៀលប្រាយ ជំនាញ គ្រប់គ្រងទូទៅនៅឆ្នាំ២០០៨ និងធ្លាប់បានចូលរួមវគ្គហ្វឹកហ្វឺនជាច្រើនទាក់ទង នឹងការគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ។ លោក ត្រូវបានតែងតាំងជា ប្រធានមុខងារប្រតិបត្តិតាម។ មុនពេលចូលបម្រើ ការងារជាមួយ និរន្តរ លោកធ្លាប់មានបទពិសោធន៍ ជាអ្នកធ្វើ និងគ្រប់គ្រងការងារដ្ឋបាលអស់រយៈពេលជាច្រើនឆ្នាំ នៅធនាគារ អេស៊ីលីដាកីអិលស៊ី។

លោក យ៉ន យ៉ែន

(នាយកនាយកដ្ឋានឥណទាន)

សញ្ជាតិខ្មែរ កើតនៅឆ្នាំ១៩៨៣ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ពីសាកលវិទ្យាល័យឯកទេសនៃកម្ពុជា ជំនាញគ្រប់គ្រងទូទៅ នៅឆ្នាំ២០១៥។លោកត្រូវបានតែងតាំងជា នាយកនាយកឥណទានក្នុងឆ្នាំ ២០២៣ ។មុនចូលបម្រើការងារជាមួយនិរន្តរ លោកធ្លាប់មានបទពិសោធន៍ជានាយកនាយកដ្ឋានផ្នែកលក់អស់រយៈពេលច្រើនឆ្នាំ នៅក្រុមហ៊ុន លី ហួរ កី អិល ស៊ី។





លោក ឡេង លីក្ន

(នាយកនាយកដ្ឋានហិរញ្ញវត្ថុ)

សញ្ជាតិខ្មែរ កើតនៅឆ្នាំ១៩៨២លោកទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យន័រតុន ជំនាញធនាគារ និងហិរញ្ញវត្ថុ នៅឆ្នាំ២០១៥ និងកំពុងបន្តការសិក្សាថ្នាក់ ACCA នៅវិទ្យាស្ថាន CamEd ។ លោកធ្លាប់បានចូលរួមវគ្គហ្វឹកហ្វឺនជាច្រើនទាក់ទង នឹងការគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ។ លោកត្រូវបានតែងតាំងជា នាយកនាយកដ្ឋានហិរញ្ញវត្ថុ ក្នុងឆ្នាំ ២០២០។ មុនពេលចូលបម្រើការងារជាមួយនិរន្តរ លោកធ្លាប់មានបទពិសោធន៍ជាអ្នកធ្វើ និងគ្រប់គ្រងការងារ សវនកម្មផ្ទៃក្នុងនៅធនាគារ អេស៊ីលីដា កីអិលស៊ី ជាច្រើនឆ្នាំ។

លោក ឈុន សុភា

(នាយកនាយកដ្ឋានធនធានមនុស្ស)



សញ្ជាតិខ្មែរកើតនៅឆ្នាំ១៩៨៨ លោកបានទទួលសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅឆ្នាំ២០១៣ លើជំនាញហិរញ្ញវត្ថុ និងធនាគារ ពីសកលវិទ្យាល័យ អាស៊ីអឺរ៉ុប ។លោកបានចូលបម្រើការងារជំបូងជាមួយនិរន្តរ ក្នុងឆ្នាំ ២០១៦ តួនាទីជា មន្ត្រីឥណទាន ហើយលោកត្រូវបានជំឡើងតួនាទីជា អនុប្រធាននាយកដ្ឋានឥណទាន ក្នុងឆ្នាំ២០២០។ ចុងក្រោយលោកត្រូវបានតែងតាំងជានាយក នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល ក្នុងឆ្នាំ២០២១។ មុនចូលបម្រើការងារជាមួយនិរន្តរ លោកមានបទពិសោធន៍ជាច្រើនឆ្នាំ លើការគ្រប់គ្រងធនធានមនុស្ស និងក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារ ។



លោក ឆាន់ ធីរក្ស

(នាយកនាយកដ្ឋានសវនកម្ម)

សញ្ជាតិខ្មែរ កើតនៅឆ្នាំ១៩៨៧ លោកទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ពីសាកលវិទ្យាល័យន័រតុន ជំនាញគ្រប់គ្រងពាណិជ្ជកម្មនៅឆ្នាំ២០១៣។ លោកធ្លាប់បានចូលរួមវគ្គហ្វឹកហ្វឺនជាច្រើនទាក់ទងនឹងសវនកម្ម និងការគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ។ លោកត្រូវបានតែងតាំងជានាយកនាយកដ្ឋាន សវនកម្មផ្ទៃក្នុងរបស់និរន្តរនៅឆ្នាំ២០២០។ មុនពេលតែងតាំងជានាយកនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់និរន្តរ លោកធ្លាប់មានបទពិសោធន៍ធ្វើជា៖ សវនករផ្ទៃក្នុង, សវនករឯកទេសផ្នែកសវនកម្ម ប្រតិបត្តិការ, សវនករជាន់ខ្ពស់ផ្នែកសវនកម្មហិរញ្ញវត្ថុ និងប្រធានផ្នែកសវនកម្មហិរញ្ញវត្ថុ ។

លោក សាំង សាវ៉ាត់

(នាយកនាយកដ្ឋានសិក្សា និងអភិវឌ្ឍន៍)



សញ្ជាតិខ្មែរ កើតនៅក្នុងឆ្នាំ ១៩៨៦ លោកបានបញ្ចាប់ថ្នាក់អនុបណ្ឌិត ជំនាញគ្រប់គ្រងអាជីវកម្ម និងថ្នាក់បរិញ្ញបត្រលើជំនាញអភិវឌ្ឍន៍សេដ្ឋកិច្ច ពីសលកវិទ្យាល័យកូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ២០១០។ លោកចូលបម្រើការងារជំបូងជាមួយនិងនិរន្តរក្នុងឆ្នាំ២០២០ ក្នុងតួនាទីជា ប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាល ហើយលោកត្រូវតម្លើងជានាយកនាយកដ្ឋានសិក្សា និងអភិវឌ្ឍន៍ នៅដើមឆ្នាំ២០២២។ មុនពេលចូលបម្រើការងារជាមួយ និរន្តរ លោកធ្លាប់មានបទពិសោធន៍ជាង១០ឆ្នាំ នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។



របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

និងរបាយការណ៍របស់សវនករឯករាជ្យ

មាតិកា

	ទំព័រ
របាយការណ៍របស់ក្រុមប្រឹក្សាភិបាល	១ - ៣
របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចៈ	
របាយការណ៍របស់សវនករឯករាជ្យ	៤ - ៧
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ	៨
របាយការណ៍ចំណូលលម្អិត	៩
របាយការណ៍បម្រែបម្រួលមូលធន	១០
របាយការណ៍លំហូរសាច់ប្រាក់	១១
កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ	១២ - ៤៤

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមដាក់ជូននូវរបាយការណ៍របស់ខ្លួនព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ៍ ភីអិលស៊ី (ហៅកាត់ថា "ក្រុមហ៊ុន") គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់។

អំពីក្រុមហ៊ុន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ៍ ភីអិលស៊ី (ហៅកាត់ថា "ក្រុមហ៊ុន") ជាក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកម្រិតដែលមានប្រតិបត្តិការនៅកម្ពុជា ក្រោមការចុះបញ្ជីលេខ ០០០០៧៤៦៩ បានចេញផ្សាយដោយក្រសួងពាណិជ្ជកម្ម ("MOC") ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣ ព្រមទាំងទទួលអាជ្ញាបណ្ណជាអចិន្ត្រៃយ៍ពីធនាគារជាតិនៃកម្ពុជា ("NBC") ដើម្បីធ្វើប្រតិបត្តិការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៥។

ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅអគារលេខ ២១-២៣-២៥ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ក្រុមហ៊ុនមាននិយោជិតចំនួន ១៩១ នាក់ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២៖ មានចំនួន ២០៤ នាក់)។

សកម្មភាពអាជីវកម្មចម្បង

ក្រុមហ៊ុនមានសកម្មភាពអាជីវកម្មចម្បងក្នុងការផ្តល់សេវាឥណទាន និងសេវាហិរញ្ញវត្ថុផ្សេងៗដល់អតិថិជនជាឯកត្តបុគ្គលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បច្ចុប្បន្នក្រុមហ៊ុនមានប្រតិបត្តិការនៅការិយាល័យកណ្តាលរបស់ខ្លួនដែលស្ថិតនៅក្នុងរាជធានីភ្នំពេញ និងសាខាចំនួន ១០ ដែលមានទីតាំងនៅខេត្តព្រះសីហនុ សៀមរាប កំពង់ស្ពឺ កណ្តាល កោះកុង កំពង់ចាម និងឧត្តរមានជ័យនៃប្រទេសកម្ពុជា។

លទ្ធផលប្រតិបត្តិការ

លទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងស្ថានភាពនៃប្រតិបត្តិការរបស់ក្រុមហ៊ុនគិតត្រឹមកាលបរិច្ឆេទនោះ ត្រូវបានកំណត់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលបានអមមកជាមួយ។

ភាគលាភ

ពុំមានភាគភាគលាភណាមួយត្រូវបានប្រកាស ឬបានបង់នោះទេ ហើយក្រុមប្រឹក្សាភិបាលក៏ពុំបានផ្តល់អនុសាសន៍ក្នុងការបង់ភាគលាភណាមួយក្នុងអំឡុងការិយបរិច្ឆេទនោះទេ។

អគារលេខ: ២១-២៣-២៥, ផ្លូវលេខ៥៩៨, សង្កាត់ភ្នំពេញថ្មី, ខណ្ឌសែនសុខ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា, ទូរស័ព្ទលេខ:០៨៦ ៦៥៥ ៩៩៩
Head Office: #21-23-25, St.598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. Tel: 086 655 999
E-mail: info@niron.com.kh, Website: www.niron.com.kh

ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនក្នុងអំឡុងការិយបរិច្ឆេទ និងរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ មានរាយនាមដូចខាងក្រោម៖

ឈ្មោះ	មុខតំណែង	កាលបរិច្ឆេទតែងតាំង/លាលែង
លោក ឈុន ស្រ៊ា	ប្រធានក្រុមប្រឹក្សាភិបាល	ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០
លោក ឈុន ស៊ីណា	អភិបាល	ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០
លោកស្រី ឈុន វ៉ាន់ណាល់	អភិបាល	ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២០/ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣
លោក ហ៊ីង កុលសំណាង	អភិបាលឯករាជ្យ	ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២

ភាគកម្មរបស់អភិបាល

ភាគកម្មរបស់អភិបាលត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ ១៣ នៃរបាយការណ៍ហិរញ្ញវត្ថុ។

សវនករ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនប្រ្គេន សនថុន (ខេមបូឌា) លីមីធីត។

អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុង និងនាចុងការិយបរិច្ឆេទនេះ ពុំមានការរៀបចំណាមួយដែលក្រុមហ៊ុន មានគោលបំណងអនុញ្ញាតឱ្យក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនទទួលបាននូវអត្ថប្រយោជន៍តាមរយៈការជាវភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬសាជីវកម្មស្ថាប័នផ្សេងទៀតនោះទេ។

ចាប់តាំងពីចុងការិយបរិច្ឆេទមុន ពុំមានសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបានអត្ថប្រយោជន៍ណាមួយឡើយ (ក្រៅពីអត្ថប្រយោជន៍ដែលរួមបញ្ចូលនៅក្នុងសមតុល្យនៃប្រាក់បំណាច់ដែលទទួលបាន ឬដល់ពេលកំណត់ និងអាចទទួលបានដោយក្រុមប្រឹក្សាភិបាល ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) ក្រោមហេតុផលនៃកិច្ចសន្យាដែលធ្វើឡើងដោយក្រុមហ៊ុន ឬសាជីវកម្មដែលពាក់ព័ន្ធជាមួយក្រុមហ៊ុនដែលមានអភិបាលជាសមាជិក ឬជាមួយក្រុមហ៊ុនដែលអភិបាលមានផលប្រយោជន៍ជាសារវន្តនៃផ្នែកហិរញ្ញវត្ថុ ក្រៅពីប្រតិបត្តិការដែលមានភ្ជាប់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនោះទេ។

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានទំនួលខុសត្រូវក្នុងការអះអាងបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងសមស្របដោយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្តពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលតម្រូវឱ្យ៖

១. អនុម័តគោលនយោបាយគណនេយ្យឱ្យបានសមស្រប ដែលអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូច និងមធ្យម ("CIFRS for SMEs") ដែលគាំទ្រដោយសមហេតុផល និងផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានប្រកបដោយភាពហ្មត់ចត់ និងប្រុងប្រយ័ត្ន ហើយអនុវត្តគោលនយោបាយទាំងនេះឱ្យមានសង្គតិភាព

២. អនុលោមតាមគោលការណ៍ដែលតម្រូវដោយស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយដែលតម្រូវឱ្យមាននៃស្តង់ដានេះក្នុងការបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវ ត្រូវប្រាកដថាការប្រាសចាកទាំងនេះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

៣. រក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព

៤. រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋានបន្តនិរន្តរភាព លើកលែងតែវាមិនសមស្របក្នុងការសន្មតថា ក្រុមហ៊ុនអាចនឹងបន្តប្រតិបត្តិការអាជីវកម្មរបស់ខ្លួនបាននាពេលអនាគត និង

៥. ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធភាព និងចូលរួមរាល់សេចក្តីសម្រេចសំខាន់ៗទាំងអស់ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថារាល់ការសម្រេចចិត្តនេះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ហើយក៏ត្រូវចាត់វិធានការឱ្យសមស្របដើម្បីទប់ស្កាត់ និងរកឱ្យឃើញការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលសូមបញ្ជាក់ថា ក្រុមហ៊ុនបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់នានាដូចដែលបានបញ្ជាក់ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ។

សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល អមមកជាមួយរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ ព្រមទាំងកំណត់សម្គាល់នានា ត្រូវបានរៀបចំឡើងយ៉ាងសមស្រប និងបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូច និងមធ្យម និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

ជំនួសឱ្យក្រុមប្រឹក្សាភិបាល

NIRON MICROFINANCE PLC KINGDOM OF CAMBODIA

លោក ឈុន ស៊ីណា
អភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤

ហ្គ្រែន សនថុន (ខេមបូឌា) លីមីធីត
ជាន់ទី២០ អគារកាណាឌីយ៉ា
៣១៥ ផ្លូវព្រះអង្គឌួង
(កែងមហាវិថីព្រះមុនីវង្ស)
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
លេខទូរស័ព្ទ +៨៥៥ ២៣ ៩៦៦ ៥២០

របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះភាគហ៊ុនិកនៃ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី

មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី (ហៅកាត់ថា "ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងរបាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន របាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងសេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ និងសេចក្តីពន្យល់ព័ត៌មានផ្សេងទៀត។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្តលើស្ថានភាពហិរញ្ញវត្ថុរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម ("CIFRS for SMEs") រួមជាមួយនិងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា ("NBC")។

មូលដ្ឋាននៃមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា ("CISAs")។ ការទទួលខុសត្រូវរបស់យើងខ្ញុំ យោងតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា ត្រូវបានបរិយាយបន្ថែមនៅក្នុងផ្នែកនៃការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនៃផ្នែករបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានឯករាជ្យភាពពីក្រុមហ៊ុនដោយអនុលោមតាមក្រមប្រឹក្សាស្តង់ដាវិជ្ជាជីវៈគណនេយ្យអន្តរជាតិ ក្រមសីលធម៌របស់គណនេយ្យករជំនាញ (រួមទាំងស្តង់ដាឯករាជ្យអន្តរជាតិ) ("IESBA Code") រួមជាមួយនឹងតម្រូវការក្រមសីលធម៌ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំបានបំពេញការទទួលខុសត្រូវទៅតាមតម្រូវការក្រមសីលធម៌ទាំងនោះ និង IESBA Code ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្ម ដែលយើងខ្ញុំទទួលបានគឺគ្រប់គ្រាន់និងសមស្រប ដើម្បីផ្តល់មូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។

គណនេយ្យករជំនាញ និងសវនករប្រតិស្រុក
ក្រុមហ៊ុន ហ្គ្រែន សនថុន (ខេមបូឌា) លីមីធីត គឺជាសមាជិករបស់ក្រុមហ៊ុនហ្គ្រែន សនថុន អន្តរជាតិ (ហ្គ្រែន សនថុន អន្តរជាតិ)។ ហ្គ្រែន សនថុន គឺសំដៅដល់ឈ្មោះដែលសមាជិករបស់ក្រុមហ៊ុនហ្គ្រែន សនថុនធ្វើប្រតិបត្តិការ និងសំដៅដល់ក្រុមហ៊ុនមួយ ឬក្រុមហ៊ុនជាសមាជិកច្រើន តាមបរិបទតម្រូវ។ ហ្គ្រែន សនថុន អន្តរជាតិ និងសមាជិកមិនមែនជាដៃគូពាណិជ្ជកម្មទូទាំងសកលលោកទេ។ រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ ហើយសេវាកម្ម ឬសកម្មភាពនៃសមាជិកនីមួយៗមិនមែនជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនហ្គ្រែន សនថុនផ្សេងទៀតទេ។

Grant Thornton

ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រង មានទំនួលខុសត្រូវទាំងស្រុងទៅលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ក៏ប៉ុន្តែមិនរាប់បញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ដែលទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ និងរបាយការណ៍ប្រចាំឆ្នាំ ដែលរំពឹងទុកថានឹងរៀបចំរួចរាល់សម្រាប់យើងខ្ញុំបន្ទាប់ពីកាលបរិច្ឆេទនោះ។

បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនសវនករផ្សេងទៀតដែលបានបញ្ចេញមតិយោបល់ត្រឹមត្រូវលើរបាយការណ៍ហិរញ្ញវត្ថុទាំងនោះនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣។

មតិយោបល់របស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុមិនបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗទេ ហើយយើងខ្ញុំមិនផ្តល់សេចក្តីសន្និដ្ឋានក្នុងទម្រង់នៃការធានាបែបណាមួយឡើយ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ យើងខ្ញុំមានទំនួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានវិសមភាពជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុឬទេ ឬចំណេះដឹងរបស់យើងខ្ញុំ ដែលទទួលបានពីការធ្វើសវនកម្មថា តើព័ត៌មានទាំងនោះ អាចមានកំហុសឆ្គងជាសារវន្តឬទេ។

ប្រសិនបើយោងតាមការងារដែលយើងបានអនុវត្ត យើងខ្ញុំសន្និដ្ឋានថាបើមានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

នៅពេលដែលយើងខ្ញុំអានរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តណាមួយកើតមានឡើង យើងខ្ញុំត្រូវធ្វើការទាក់ទងជាមួយក្រុមប្រឹក្សាភិបាល និងទទួលខុសត្រូវលើបញ្ហាទាំងនេះដោយអនុលោមតាមការតម្រូវរបស់ CISA ៧២០ (បានធ្វើការកែតម្រូវ)។

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឱ្យបានត្រឹមត្រូវដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម និងការទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលក្រុមប្រឹក្សាភិបាលកំណត់ថាវាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនឱ្យមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវចំពោះការវាយតម្លៃសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តប្រតិបត្តិការដោយផ្អែកលើមូលដ្ឋាននិរន្តរភាព ការលាតត្រដាង និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពជាមូលដ្ឋានគណនេយ្យ លុះត្រាតែក្រុមប្រឹក្សាភិបាលមានគោលបំណងរំសាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេងប៉ុន្តែចាំបាច់ត្រូវធ្វើ។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

គណនេយ្យករជំនាញ និងសវនករប្រតិស្រុត
ក្រុមហ៊ុន ប្រ្តេន សនថុន (ខេមបូឌា) លីមីធីត គឺជាសមាជិករបស់ក្រុមហ៊ុនប្រ្តេន សនថុន អន្តរជាតិ (ប្រ្តេន សនថុន អន្តរជាតិ)។ ប្រ្តេន សនថុន គឺសំដៅដល់ឈ្មោះដែលសមាជិករបស់ក្រុមហ៊ុនប្រ្តេន សនថុនធ្វើប្រតិបត្តិការ និងសំដៅដល់ក្រុមហ៊ុនមួយ ឬក្រុមហ៊ុនជាសមាជិកច្រើន តាមបរិបទតម្រូវ។ ប្រ្តេន សនថុន អន្តរជាតិ និងសមាជិកមិនមែនជាដៃគូពាណិជ្ជកម្មទូទាំងសកលលោកទេ។ រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ ហើយសេវាកម្ម ឬសកម្មភាពនៃសមាជិកនីមួយៗមិនមែនជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនប្រ្តេន សនថុនផ្សេងទៀតទេ។

Grant Thornton

ការឆ្លុះបញ្ចាំងរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផល ទៅលើរបាយការណ៍ហិរញ្ញវត្ថុដោយពុំមានលក្ខណៈខុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង និងការធ្វើរបាយការណ៍សវនកម្មដែលរួមមានមតិយោបល់របស់យើងខ្ញុំផងដែរ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាមួយដ៏ខ្ពស់ ប៉ុន្តែវាមិនបានធានាថាការធ្វើសវនកម្មដោយផ្អែកទៅលើស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា នឹងតែងតែរកឃើញនូវការរាយការណ៍ខុសជាសារវន្តដែលកើតមានឡើងនោះឡើយ។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្អែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ផ្អែកមួយនៃការធ្វើសវនកម្មដោយយោងទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវវិជ្ជាជីវៈវិនិច្ឆ័យនិងរក្សាមជ្ឈភាពនិយមប្រកបដោយវិជ្ជាជីវៈទៅលើការធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- កំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យនៃការរាយការណ៍ខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុថាតើវាកើតឡើងដោយការក្លែងបន្លំ ឬកំហុសឆ្គងដោយអចេតនា រៀបចំនិងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្របដើម្បីជាមូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសឆ្គងដោយអចេតនាដោយសារតែការក្លែងបន្លំរួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំដោយចេតនា ការលុបចោលដោយចេតនា ការបង្ហាញខុស ឬការល្មើសទៅលើការត្រួតពិនិត្យផ្ទៃក្នុង។
- ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុងដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនីតិវិធីសវនកម្មដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។
- ធ្វើការវាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន ក៏ដូចជាការបង្ហាញនានាដែលធ្វើឡើងដោយក្រុមប្រឹក្សាភិបាល។
- សន្និដ្ឋានដ៏សមស្របមួយទៅលើការប្រើប្រាស់របស់ក្រុមប្រឹក្សាភិបាលលើមូលដ្ឋាននិរន្តរភាពគណនេយ្យផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលធ្វើឱ្យមានមន្ទិលសង្ស័យខ្លាំងទៅលើលទ្ធភាពការបន្តនិរន្តរភាពរបស់ក្រុមហ៊ុន។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា ភាពមិនប្រាកដប្រជាជាសារវន្តនឹងកើតមានឡើង យើងខ្ញុំតម្រូវឱ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ដើម្បីទាញការយកចិត្តទុកដាក់នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំទៅនឹងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬក៏ប្រសិនបើការលាតត្រដាងនោះមិនគ្រប់គ្រាន់ នោះមតិយោបល់មិនត្រឹមត្រូវនឹងត្រូវបានផ្តល់។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានគិតត្រឹមថ្ងៃនៃការចេញរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះបីយ៉ាងណាក៏ដោយស្ថានភាព ឬក៏ព្រឹត្តិការណ៍នាពេលអនាគតអាចបណ្តាលឱ្យក្រុមហ៊ុនមិនអាចបន្តប្រតិបត្តិការជានិរន្តរភាពបាន។
- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងមាតិការបស់របាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងការលាតត្រដាងនានាថាតើរបាយការណ៍ហិរញ្ញវត្ថុបង្ហាញនូវប្រតិបត្តិការ និងព្រឹត្តិការណ៍នានាបានបង្ហាញនូវភាពត្រឹមត្រូវសមស្របរបស់វាដែរឬទេ។

គណនេយ្យការជំនាញ និងសវនការប្រតិស្រុត
ក្រុមហ៊ុន ប្រេន សនថុន (ខេមបូឌា) លីមីធីត គឺជាសមាជិករបស់ក្រុមហ៊ុនប្រេន សនថុន អន្តរជាតិ (ប្រេន សនថុន អន្តរជាតិ)។ ប្រេន សនថុន គឺសំដៅដល់ឈ្មោះដែលសមាជិករបស់ក្រុមហ៊ុនប្រេន សនថុនធ្វើប្រតិបត្តិការ និងសំដៅដល់ក្រុមហ៊ុនមួយ ឬក្រុមហ៊ុនជាសមាជិកច្រើន តាមបរិបទតម្រូវ។ ប្រេន សនថុន អន្តរជាតិ និងសមាជិកមិនមែនជាដៃគូពាណិជ្ជកម្មទូទាំងសកលលោកទេ។ រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ ហើយសេវាកម្ម ឬសកម្មភាពនៃសមាជិកនីមួយៗមិនមែនជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនប្រេន សនថុនផ្សេងទៀតទេ។

Grant Thornton

យើងខ្ញុំប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាលទៅលើបញ្ហាផ្សេងៗ កំណត់វិសាលភាព និងពេលវេលាក្នុងការធ្វើសវនកម្ម និងរបកគំហើញសវនកម្មសំខាន់ៗ រួមបញ្ចូលទាំងកង្វះខាតសំខាន់ៗមួយចំនួនទៅលើការគ្រប់គ្រងផ្ទៃក្នុងដែលយើងខ្ញុំបានរកឃើញអំឡុងពេលធ្វើសវនកម្ម។

ប្រ្តេន សនថុន (ខេមបូឌា) លីមីធីត
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

Ng Yee Zent
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤

គណនេយ្យករជំនាញ និងសវនករប្រតិស្រុត
ក្រុមហ៊ុន ប្រ្តេន សនថុន (ខេមបូឌា) លីមីធីត គឺជាសមាជិករបស់ក្រុមហ៊ុនប្រ្តេន សនថុន អន្តរជាតិ (ប្រ្តេន សនថុន អន្តរជាតិ)។ ប្រ្តេន សនថុន គឺសំដៅដល់ឈ្មោះដែលសមាជិករបស់ក្រុមហ៊ុនប្រ្តេន សនថុនធ្វើប្រតិបត្តិការ និងសំដៅដល់ក្រុមហ៊ុនមួយ ឬក្រុមហ៊ុនជាសមាជិកច្រើន តាមបរិបទតម្រូវ។ ប្រ្តេន សនថុន អន្តរជាតិ និងសមាជិកមិនមែនជាដៃគូពាណិជ្ជកម្មខុទាំងសកលលោកទេ។ រាល់សេវាកម្មនានាត្រូវបានផ្តល់ជាំងឯករាជ្យដោយសមាជិកនីមួយៗ ហើយសេវាកម្ម ឬសកម្មភាពនៃសមាជិកនីមួយៗមិនមែនជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនប្រ្តេន សនថុនផ្សេងទៀតទេ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ៍ គីអិលស៊ី
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

	កំណត់សម្គាល់	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ៣.២)	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (បានបញ្ជាក់ឡើងវិញ) ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ៣.២ និង២១)
ទ្រព្យសកម្ម					
សាច់ប្រាក់ក្នុងដៃ	៥	**៨១.៨៤០**	**៣៣៤.៣១៦**	៤៣.៨៣៥	១៨០.៤៦៩
ប្រាក់បញ្ញើតាមបទប្បញ្ញត្តិ	៦	**១៣៩.៤៨១**	**៥៦៩.៧៨០**	១៣៨.៣២៧	៥៦៩.៤៩២
ប្រាក់បញ្ញើ និងប្រាក់តម្កល់ជាមួយធនាគារផ្សេងៗ	៧	**១.១៨៤.៤៦៤**	**៤.៨៣៨.៥៣៥**	១.៦៩៣.៣១៥	៦.៩៧១.៣៧៨
ឥណទានផ្តល់ជូនអតិថិជន	៨	**២.០០៤.៧៦៤**	**៨.១៨៩.៤៦១**	១.៩១១.៥៨៦	៧.៨៧០.០០០
ទ្រព្យសកម្មផ្សេងៗ	៩	**១៥០.០៣២**	**៦១២.៨៨១**	១៦១.៤២៧	៦៦៤.៥៩៥
ទ្រព្យសម្បត្តិ និងបរិក្ខារ	១០	**៧១.៣៤១**	**២៩១.៤២៨**	១០៨.១៩៤	៤៤៥.៤៣៥
ទ្រព្យសកម្មពន្ធពន្យារសុទ្ធ	១២(គ)	**១២៣.២២៣**	**៥០៣.៣៦៦**	៤១.៣០២	១៧០.០៤០
ទ្រព្យសកម្មសរុប		**៣.៧៥៥.១៤៥**	**១៥.៣៣៩.៧៦៧**	៤.០៩៧.៩៨៦	១៦.៨៧១.៤០៩
បំណុល និងមូលធន					
បំណុល					
គណនីត្រូវសងផ្សេងៗ	១១	**៩៦.៦៦៥**	**៣៩៤.៨៧៧**	៩០.៣៩៤	៣៧២.១៥២
បំណុលពន្ធអប្បបរមា/បំណុលពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន	១២(ឃ)	**១.៥២១**	**៦.២១៣**	១.៦៣១	៦.៧១៥
បំណុលសរុប		**៩៨.១៨៦**	**៤០១.០៩០**	៩២.០២៥	៣៧៨.៨៦៧
មូលធន					
ដើមទុន	១៣	**២.៥៥៧.៧៦៥**	**១០.២៣១.០៦០**	២.៥៥៧.៧៦៥	១០.២៣១.០៦០
ចំណេញរក្សាទុក		**១.០៩៩.១៩៤**	**៤.៤៣២.៦៤៨**	១.៤៤៨.១៩៦	៥.៨៦៧.០៤៥
លម្អៀងពីការប្តូររូបិយប័ណ្ណ		**-**	**២៧៤.៩៦៩**	-	៣៩៤.៤៣៧
មូលធនសរុប		**៣.៦៥៦.៩៥៩**	**១៤.៩៣៨.៦៧៧**	៤.០០៥.៩៦១	១៦.៤៩២.៥៤២
បំណុល និងមូលធនសរុប		**៣.៧៥៥.១៤៥**	**១៥.៣៣៩.៧៦៧**	៤.០៩៧.៩៨៦	១៦.៨៧១.៤០៩

ត្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ៍ តីអិលស៊ី
របាយការណ៍ចំណូលលម្អិត
សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

				(បានបញ្ជាក់ឡើងវិញ)	
		សម្រាប់ដំណាច់ការិយបរិច្ឆេទ		សម្រាប់ដំណាច់ការិយបរិច្ឆេទ	
		ដែលបានបញ្ចប់		ដែលបានបញ្ចប់	
	កំណត់	**ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	សម្គាល់	**ដុល្លារអាមេរិក**	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
		(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២ និង២១)	
ចំណូលប្រតិបត្តិការ					
ចំណូលការប្រាក់	១៤	**៤៦៣.២២៩**	**១.៩០៣.៨៧១**	៤២៣.៩០៥	១.៧៣២.៥០០
ចំណូលកម្រៃសេវា និងកម្រៃជើងសា	១៥	**១.២១៥.៧០៨**	**៤.៩៩៦.៥៦០**	១.៥០៦.៥១៦	៦.១៥៧.១៣១
ចំណូលការប្រាក់សុទ្ធ		**១.៦៧៨.៩៣៧**	**៦.៩០០.៤៣១**	១.៩៣០.៤២១	៧.៨៨៩.៦៣១
ចំណូលប្រតិបត្តិការផ្សេងៗ	១៦	**៩៩.០០៨**	**៤០៦.៩២៣**	៨២.៦៧២	៣៣៧.៨៨០
ចំណូលប្រតិបត្តិការសុទ្ធ		**១.៧៧៧.៩៤៥**	**៧.៣០៧.៣៥៤**	២.០១៣.០៩៣	៨.២២៧.៥១១
រំលស់	១០	**(៤១.០៩៣)**	**(១៦៨.៨៩២)**	(៣៧.៦៩៩)	(១៥៤.០៧៦)
ចំណាយទូទៅ និងចំណាយរដ្ឋបាល	១៧	**(១.៨០៨.៩៥៩)**	**(៧.៤៣៤.៨២១)**	(១.៧៤១.៩៤៦)	(៧.១១៩.៣៣៣)
ការខាតបង់ឱនភាពតម្លៃសុទ្ធលើទ្រព្យសកម្មហិរញ្ញវត្ថុ	៨	**(៣៤១.២៤៥)**	**(១.៤០២.៥១៧)**	(១៩៥.៧៥៦)	(៨០០.០៥៥)
(ខាត)/ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល		**(៤១៣.៣៥២)**	**(១.៦៩៨.៨៧៦)**	៣៧.៦៩២	១៥៤.០៤៧
ឥណទាន/(ចំណាយ)ពន្ធលើប្រាក់ចំណូល	១២(ក)	**៦៤.៣៥០**	**២៦៤.៤៧៩**	(៣.៦៧៥)	(១៥.០២០)
(ខាត)/ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ		**(៣៤៩.០០២)**	**(១.៤៣៤.៣៩៧)**	៣៤.០១៧	១៣៩.០២៧
ចំណូលលម្អិតផ្សេងៗ					
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	**(១១៩.៤៦៨)**	-	១៧១.៨១៤
(ខាត)/ចំណេញលម្អិតក្នុងការិយបរិច្ឆេទសរុប		**(៣៤៩.០០២)**	**(១.៥៥៣.៨៦៥)**	៣៤.០១៧	៣១០.៨៤១

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ៍ តីអិលស៊ី
របាយការណ៍បម្រែបម្រួលមូលធន
សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

	ដុល្លារអាមេរិក	ដើមទុន ពាន់រៀល (កំណត់សម្គាល់ ៣.២)	ដុល្លារអាមេរិក	ចំណេញរក្សាទុក ពាន់រៀល (កំណត់សម្គាល់ ៣.២ និង២១)	លម្អៀងពីការប្តូរ រូបិយប័ណ្ណ ពាន់រៀល (កំណត់សម្គាល់ ៣.២)	ដុល្លារអាមេរិក	សរុប ពាន់រៀល (កំណត់សម្គាល់ ៣.២)
សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២៣	**២.៥៥៧.៧៦៥**	**១០.២៣១.០៦០**	**១.៤៤៨.១៩៦**	**៥.៨៦៧.០៤៥**	**៣៩៤.៤៣៧**	**៤.០០៥.៩៦១**	**១៦.៤៩២.៥៤២**
ខាតសុទ្ធក្នុងការិយបរិច្ឆេទ	-	-	**(៣៤៩.០០២)**	**(១.៤៣៤.៣៩៧)**	-	**(៣៤៩.០០២)**	**(១.៤៣៤.៣៩៧)**
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	**(១១៩.៤៦៨)**	-	**(១១៩.៤៦៨)**
សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣	**២.៥៥៧.៧៦៥**	**១០.២៣១.០៦០**	**១.០៩៩.១៩៤**	**៤.៤៣២.៦៤៨**	**២៧៤.៩៦៩**	**៣.៦៥៦.៩៥៩**	**១៤.៩៣៨.៦៧៧**
(បានបញ្ជាក់ឡើងវិញ)							
សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២២	២.៥៥៧.៧៦៥	១០.២៣១.០៦០	១.៤១៤.១៧៩	៥.៧២៨.០១៨	២២២.៦២៣	៣.៩៧១.៩៤៤	១៦.១៨១.៧០១
ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ	-	-	៣៤.០១៧	១៣៩.០២៧	-	៣៤.០១៧	១៣៩.០២៧
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	១៧១.៨១៤	-	១៧១.៨១៤
សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	២.៥៥៧.៧៦៥	១០.២៣១.០៦០	១.៤៤៨.១៩៦	៥.៨៦៧.០៤៥	៣៩៤.៤៣៧	៤.០០៥.៩៦១	១៦.៤៩២.៥៤២

ត្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ៍ តីអិលស៊ី
របាយការណ៍លំហូរសាច់ប្រាក់
សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

				(បានបញ្ជាក់ឡើងវិញ)	
		សម្រាប់ដំណាច់ការិយបរិច្ឆេទ		សម្រាប់ដំណាច់ការិយបរិច្ឆេទ	
		ដែលបានបញ្ចប់		ដែលបានបញ្ចប់	
	កំណត់	**ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	សម្គាល់	**ដុល្លារអាមេរិក**	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
		(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២ និង២១)	
សកម្មភាពប្រតិបត្តិការ					
(ខាត)/ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ		**(៤១៣.៣៥២)**	**(១.៦៩៨.៨៧៦)**	៣៧.៦៩២	១៥៤.០៤៧
និយ័តកម្មសម្រាប់៖					
ការខាតបង់ឱនភាពតម្លៃសុទ្ធលើទ្រព្យសកម្មហិរញ្ញវត្ថុ	៨	**៣៤១.២៤៥**	**១.៤០២.៥១៧**	១៩៥.៧៥៦	៨០០.០៥៥
រំលស់	១០	**៤១.០៩៣**	**១៦៨.៨៩២**	៣៧.៦៩៩	១៥៤.០៧៦
ឥណទានរៀបចំឡើងវិញ	១៦	**(៥២.១៤៨)**	**(២១៤.៣២៨)**	(៣៣.៧០៤)	(១៣៧.៧៤៨)
ខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ	១៧	**៣៨២**	**១.៥៧០**	-	-
(ខាត)/ចំណូលប្រតិបត្តិការមុនបម្រែបម្រួលដើមទុនបង្វិលបម្រែបម្រួលដើមទុនបង្វិល៖		**(៨២.៧៨០)**	**(៣៤០.២២៥)**	២៣៧.៤៤៣	៩៧០.៤៣០
ឥណទានផ្តល់ជូនអតិថិជន	៨	**(៣៨២.២៧៥)**	**(១.៥៧១.១៥០)**	(៥៥.៤៥៤)	(២២៦.៦៤០)
ទ្រព្យសកម្មផ្សេងៗ	៩	**១១.៣៩៦**	**៤៦.៨៣៨**	២.៨១២	១១.៤៩៣
គណនីត្រូវសងផ្សេងៗ	១១	**៦.២៧០**	**២៥.៧៧០**	(៨៨.១៨៥)	(៣៦០.៤១២)
សាច់ប្រាក់(បានប្រើក្នុង)/បានមកពីប្រតិបត្តិការ		**(៤៨៧.៣៨៩)**	**(១.៨៣៨.៧៦៧)**	៩៦.៦១៦	៣៩៤.៨៧១
ពន្ធអប្បបរមា/ពន្ធលើប្រាក់ចំណូលដែលបានបង់		**(១៧.៦៨១)**	**(៧២.៦៦៩)**	(២២.៦០៥)	(៩២.៣៨៧)
សាច់ប្រាក់សុទ្ធ(បានប្រើក្នុង)/ បានមកពីសកម្មភាពប្រតិបត្តិការ		**(៤៦៥.០៧០)**	**(១.៩១១.៤៣៦)**	៧៤.០១១	៣០២.៤៨៤
សាច់ប្រាក់បានប្រើក្នុងសកម្មភាពវិនិយោគ					
ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ	១០	**(៤.៨៥០)**	**(១៩.៩៣១)**	(៤៨.៩៤៧)	(២០០.០៤៦)
សាច់ប្រាក់ដែលទទួលបានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ		**២២៨**	**៩៣៧**	-	-
សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ		**(៤.៦២២)**	**(១៨.៩៩៤)**	(៤៨.៩៤៧)	(២០០.០៤៦)
(ការថយចុះ)/ការកើនឡើងក្នុងសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ		**(៤៦៩.៦៩២)**	**(១.៩៣០.៤៣១)**	២៥.០៦៤	១០២.៤៣៧
សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមការិយបរិច្ឆេទ		**១.៧៤៧.៥៨៩**	**៧.១៩៤.៨២៤**	១.៧២២.៥២៥	៧.០១៧.៥៦៧
លម្អៀងពីការប្តូររូបិយប័ណ្ណ		**-**	**(៤៤.១៨៤)**	-	៧៤.៨២០
សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងការិយបរិច្ឆេទ	១៨	**១.២៧៧.៨៩៧**	**៥.២២០.២០៩**	១.៧៤៧.៥៨៩	៧.១៩៤.៨២៤

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ៍ គីអិលស៊ី
កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់

១. ព័ត៌មានទូទៅពីក្រុមហ៊ុន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ៍ គីអិលស៊ី (ហៅកាត់ថា "ក្រុមហ៊ុន") ជាក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកម្រិតដែលមានប្រតិបត្តិការនៅកម្ពុជា ក្រោមការចុះបញ្ជីលេខ ០០០០៧៤៦៩ បានចេញផ្សាយដោយក្រសួងពាណិជ្ជកម្ម ("MOC") ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣ ព្រមទាំងទទួលអាជ្ញាបណ្ណជាអចិន្ត្រៃយ៍ពីធនាគារជាតិនៃកម្ពុជា ("NBC") ដើម្បីធ្វើប្រតិបត្តិការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៥។

ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅអគារលេខ ២១-២៣-២៥ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនមានសកម្មភាពអាជីវកម្មចម្បងក្នុងការផ្តល់សេវាឥណទាន និងសេវាហិរញ្ញវត្ថុផ្សេងៗដល់អតិថិជនជាឯកត្តបុគ្គលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បច្ចុប្បន្នក្រុមហ៊ុនមានប្រតិបត្តិការនៅការិយាល័យកណ្តាលរបស់ខ្លួនដែលស្ថិតនៅក្នុងរាជធានីភ្នំពេញ និងសាខាចំនួន ១០ ដែលមានទីតាំងនៅខេត្តព្រះសីហនុ សៀមរាប កំពង់ស្ពឺ កណ្តាល កោះកុង កំពង់ចាម និងឧត្តរមានជ័យនៃប្រទេសកម្ពុជា។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ក្រុមហ៊ុនមាននិយោជិតចំនួន ១៩១ នាក់ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២៖ មានចំនួន ២០៤ នាក់)។

២. របាយការណ៍អនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូច និងមធ្យម

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូច និងមធ្យម ("CIFRS for SMEs") ដែលត្រូវបានអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្រោមប្រកាសលេខ ០៦៨ ប្រ.ក សហវ នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០០៩ និងនិយ័តករគណនេយ្យ និងសវនកម្មនៃកម្ពុជាតាមសេចក្តីជូនដំណឹងលេខ ០៩៧/០៩ សហវ ចុះនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ដោយមិនមានការកែប្រែឡើយ។ ស្តង់ដារនេះសំដៅដល់ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូច និងមធ្យម។

៣. គោលនយោបាយគណនេយ្យសំខាន់ៗ

៣.១ មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ("USD") ត្រូវបានរៀបចំឡើងតាមអនុសញ្ញាថ្លៃដើមប្រវត្តិសាស្ត្រ និងអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម។

៣.២ រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់បង្ហាញ

រូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺខ្មែររៀល ("KHR")។ ប៉ុន្តែដោយសារក្រុមហ៊ុនមានប្រតិបត្តិការអាជីវកម្ម និងការរក្សាកំណត់ត្រាគណនេយ្យបឋមជាប្រាក់ដុល្លារអាមេរិក គណៈគ្រប់គ្រងបានកំណត់យករូបិយប័ណ្ណដុល្លារអាមេរិកជារូបិយប័ណ្ណរបស់ក្រុមហ៊ុនសម្រាប់គោលបំណងនៃការវាស់វែង និងបង្ហាញព្រោះវាបានឆ្លុះបញ្ចាំងពីខ្លឹមសារសេដ្ឋកិច្ចនៃព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន។

ប្រតិបត្តិការជារូបិយប័ណ្ណបរទេសក្រៅពីដុល្លារអាមេរិក ត្រូវបានប្តូរទៅជាដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់ទូទៅនៅកាលបរិច្ឆេទនៃប្រតិបត្តិការ។ ទ្រព្យសកម្ម ឬបំណុលហិរញ្ញវត្ថុ ដែលកំណត់ជារូបិយប័ណ្ណក្រៅពីដុល្លារអាមេរិកនាកាលបរិច្ឆេទនៃរបាយការណ៍ត្រូវបានប្តូរទៅជាដុល្លារអាមេរិកដោយប្រើប្រាស់អត្រាប្តូរប្រាក់ទូទៅនៅកាលបរិច្ឆេទនៃរបាយការណ៍។ ភាពខុសគ្នាពីការប្តូររូបិយប័ណ្ណ ដែលបានកើតឡើងពីការប្តូរប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិត។

ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិក ទៅជាខ្មែររៀលដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានដាក់បញ្ចូលទាំងស្រុងដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្មនៃកម្ពុជាចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដោយប្រើប្រាស់អត្រាប្តូរប្រាក់ជាផ្លូវការដែលបានបង្ហាញជាប្រាក់រៀលដោយយោងទៅតាមអត្រាប្តូរប្រាក់ក្នុង ១ដុល្លារអាមេរិក ចេញផ្សាយដោយធនាគារជាតិនៃកម្ពុជាដូចខាងក្រោម៖

	ឆ្នាំ២០២៣	ឆ្នាំ២០២២
អត្រាប្តូរប្រាក់ជាមធ្យម*	**៤.១១០***	៤.០៨៧
អត្រាប្តូរប្រាក់ចុងគ្រា	**៤.០៨៥**	៤.១១៧

*អត្រាប្តូរប្រាក់មធ្យម ត្រូវបានកំណត់ដោយប្រើប្រាស់អត្រាប្រចាំថ្ងៃក្នុងអំឡុងការិយបរិច្ឆេទ។

អត្រាប្តូរប្រាក់ទាំងនេះ មិនត្រូវបានធ្វើសវនកម្ម និងមិនត្រូវបានបកស្រាយថា ជាតំណាងនៃប្រាក់ដុល្លារអាមេរិក ឬដែលត្រូវបាន ឬអាចនឹងត្រូវបាន ឬអាចប្តូរទៅជាប្រាក់រៀលនៅថ្ងៃអនាគតតាមអត្រាដែលបានបង្ហាញនេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតឡើយ។

៣.៣ ការប្រាក់

ចំណូលការប្រាក់ និងចំណាយការប្រាក់ត្រូវបានទទួលស្គាល់ក្នុងគណនីចំណេញ ឬខាត ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ 'អត្រាការប្រាក់ប្រសិទ្ធភាព' គឺជាអត្រាដែលធ្វើអប្បហារជាក់ស្តែងលើការប៉ាន់ស្មាននៃការទូទាត់ និងការទទួលសាច់ប្រាក់នាពេលអនាគតតាមរយៈអាយុកាលរំពឹងទុករបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ (ឬតាមភាពសមស្របឬតាមរយៈពេលខ្លីជាងនេះ) ទៅសមតុល្យយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាព ក្រុមហ៊ុនធ្វើការប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគតដោយពិចារណាលើលក្ខខណ្ឌកិច្ចសន្យាទាំងអស់នៃឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនមែនការខាតបង់ឥណទាននាពេលអនាគតនោះទេ។

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាពរួមមានចំណាយប្រតិបត្តិការ និងកម្រៃសេវា និងការបង់សងលើសលក្ខខណ្ឌ ឬបានទទួលដែលជាផ្នែកសំខាន់មួយនៃអត្រាការប្រាក់ប្រសិទ្ធភាព។ ចំណាយប្រតិបត្តិការរួមមានចំណាយបន្ថែមដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការទិញ ឬការអនុម័តនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

៣.៤ កម្រៃសេវា និងកម្រៃជើងសា

ចំណូល និងចំណាយកម្រៃសេវា និងកម្រៃជើងសា ដែលរួមបញ្ចូលទៅនឹងអត្រាការប្រាក់ប្រសិទ្ធភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលនៅក្នុងការវាស់វែងលើអត្រាការប្រាក់ប្រសិទ្ធភាព។

ចំណូលកម្រៃសេវា និងកម្រៃជើងសាផ្សេងៗត្រូវបានទទួលស្គាល់នៅពេលដែលសេវាកម្មពាក់ព័ន្ធត្រូវបានអនុវត្ត។ ប្រសិនបើឥណទានកិច្ចសន្យាមិនត្រូវបានគេរំពឹងថានឹងមានលទ្ធផលក្នុងការដកឥណទាន នោះសេវាឥណទានកិច្ចសន្យាដែលពាក់ព័ន្ធត្រូវបានទទួលស្គាល់លើមូលដ្ឋានថេរក្នុងការិយបរិច្ឆេទនៃកិច្ចសន្យានោះ។

កម្រៃសេវា និងចំណាយជើងសាផ្សេងៗ ដែលទាក់ទងជាចម្បងទៅនឹងសេវាប្រតិបត្តិការ និងកម្រៃសេវា ដែលត្រូវបានចំណាយនៅពេលសេវាកម្មត្រូវបានទទួល។

៣.៥ ភតិសន្យា

ការទូទាត់ត្រូវបានធ្វើឡើងក្រោមភតិសន្យាប្រតិបត្តិការ ត្រូវបានទទួលស្គាល់នៅក្នុងគណនីចំណេញ ឬខាតលើមូលដ្ឋានថេរនៃលក្ខខណ្ឌកំណត់របស់ភតិសន្យា។ ការលើកទឹកចិត្តភតិសន្យាដែលបានទទួលត្រូវបានទទួលស្គាល់ជាផ្នែកសំខាន់មួយនៃចំណាយភតិសន្យាសរុបលើលក្ខខណ្ឌកំណត់របស់ភតិសន្យា។

ភតិសន្យាត្រូវបានចាត់ថ្នាក់ជាភតិសន្យាហិរញ្ញវត្ថុនៅពេលណាដែលលក្ខខណ្ឌនៃភតិសន្យាត្រូវបានផ្ទេរនូវរាល់ហានិភ័យចម្បងៗ និងភាពជាម្ចាស់កម្មសិទ្ធិនៃទ្រព្យសកម្មភតិសន្យាទៅក្រុមហ៊ុន។ ភតិសន្យាផ្សេងៗទាំងអស់ត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិការ។ សិទ្ធិប្រើប្រាស់លើទ្រព្យសកម្មដែលស្ថិតក្រោមភតិសន្យាហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ថាជាទ្រព្យសកម្មរបស់ក្រុមហ៊ុនតាមតម្លៃសមស្របនៃទ្រព្យសម្បត្តិភតិសន្យា (ឬប្រសិនបើទាបជាងតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យាអប្បបរមា) នៅកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា។ មូលដ្ឋានបំណុលរបស់ភតិក:ត្រូវបានបញ្ចូលក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុជាកាតព្វកិច្ចភតិសន្យាហិរញ្ញវត្ថុ។ ការទូទាត់ភតិសន្យាត្រូវបានបែងចែករវាងចំណាយហិរញ្ញវត្ថុ និងការកាត់បន្ថយកាតព្វកិច្ចភតិសន្យា ដើម្បីសម្រេចតាមអត្រាការប្រាក់ថេរលើសមតុល្យបំណុលដែលនៅសល់។ ចំណាយហិរញ្ញវត្ថុត្រូវបានកាត់កងតាមការវាស់វែងនៃគណនីចំណេញ ឬខាត។ ទ្រព្យសកម្មដែលស្ថិតក្រោមភតិសន្យាហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលនៅក្នុងទ្រព្យសម្បត្តិ និងបរិក្ខារ ហើយត្រូវបានរំលស់ និងធ្វើការវាយតម្លៃលើការខាតបង់ឱនភាពតម្លៃតាមរបៀបដូចគ្នាទៅនឹងម្ចាស់ទ្រព្យសកម្មផ្ទាល់។

ការទូទាត់ការជួលក្រោមភតិសន្យាប្រតិបត្តិការ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ ឬខាតតាមមូលដ្ឋានថេរនៃលក្ខខណ្ឌកំណត់របស់ភតិសន្យាដែលពាក់ព័ន្ធ។

៣.៦ ចំណាយទូទៅ និងចំណាយរដ្ឋបាល

ចំណាយទូទៅ និងចំណាយរដ្ឋបាលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិត និងខាតបង្គរក្នុងអំឡុងការិយបរិច្ឆេទដែលចំណាយទាំងនោះត្រូវបានកើតឡើង។

៣.៧ ពន្ធលើប្រាក់ចំណូល

ចំណាយពន្ធលើប្រាក់ចំណូលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិតដែលរួមបញ្ចូលទាំងផលបូកនៃពន្ធពន្យារ ហើយពន្ធបច្ចុប្បន្នមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិតផ្សេងៗ និងដោយផ្ទាល់ក្នុងគណនីមូលធនឡើយ។

ទ្រព្យសកម្មពន្ធលើប្រាក់ចំណូល និង/ឬបំណុល រួមមានកាតព្វកិច្ច ឬការទាមទារពីអាជ្ញាធរសារពើពន្ធដែលទាក់ទងនឹងចុងការិយបរិច្ឆេទនៃរបាយការណ៍បច្ចុប្បន្ន ឬពីពេលកន្លងមក ដែលមិនបានទូទាត់នាការិយបរិច្ឆេទនៃរបាយការណ៍នោះ។ ពន្ធបច្ចុប្បន្ន គឺបំណុលលើប្រាក់ចំណេញជាប់ពន្ធ ដែលខុសពីប្រាក់ចំណេញ ឬខាតក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ការគណនាពន្ធបច្ចុប្បន្ន គឺផ្អែកលើអត្រាពន្ធ និងច្បាប់ពន្ធដែលត្រូវបានអនុម័ត ឬត្រូវបានអនុម័តជាធរមាននាចុងការិយបរិច្ឆេទនៃការរាយការណ៍នីមួយៗ។

ពន្ធពន្យារលើប្រាក់ចំណូល ត្រូវបានគណនាដោយប្រើប្រាស់វិធីសាស្ត្រសមតុល្យបំណុលលើភាពខុសគ្នាជាបណ្តោះអាសន្នរវាងសមតុល្យយោងរបស់ទ្រព្យសកម្ម និងបំណុលព្រមទាំងមូលដ្ឋានពន្ធរបស់វា។ ទ្រព្យសកម្មពន្ធពន្យារ និងបំណុលពន្ធពន្យារ ត្រូវបានគណនាដោយមិនគិតអប្បហារ នៅអត្រាពន្ធដែលរំពឹងថានឹងអនុវត្តទៅតាមរយៈពេលនៃការទទួលស្គាល់របស់ពួកគេ ដោយសារអត្រាពន្ធទាំងនោះត្រូវបានអនុម័ត ឬអនុម័តជាធរមាននាចុងការិយបរិច្ឆេទនៃការរាយការណ៍នីមួយៗ។

ទ្រព្យសកម្មពន្ធពន្យារ ត្រូវបានទទួលស្គាល់ដើម្បីពង្រីកវិសាលភាពដែលប្រហែលជា មានការខាតបង់ ឬភាពខុសគ្នាបណ្តោះអាសន្នដែលកាត់កងបាន នឹងអាចប្រើប្រាស់បានដើម្បីកាត់កងនឹងប្រាក់ចំណូលជាប់ពន្ធនាពេលអនាគត។ ការវាយតម្លៃនេះ គឺផ្អែកលើការព្យាករណ៍របស់ក្រុមហ៊ុនទៅលើលទ្ធផលប្រតិបត្តិការនាពេលអនាគត ដែលត្រូវបានកែតម្រូវសម្រាប់ប្រាក់ចំណូល និងការចំណាយដែលមិនជាប់ពន្ធ និងការកំណត់ជាក់លាក់លើការប្រើប្រាស់ពន្ធខាតដែលមិនបានប្រើប្រាស់ណាមួយ និងឥណទាន។ បំណុលពន្ធពន្យារ តែងតែត្រូវបានទទួលស្គាល់ទាំងអស់។

ទ្រព្យសកម្មពន្ធពន្យារ និងបំណុលពន្ធពន្យារ អាចកាត់កងបានតែនៅពេលក្រុមហ៊ុនមានសិទ្ធិ និងគោលបំណងក្នុងការទូទាត់ពន្ធបច្ចុប្បន្នលើទ្រព្យសកម្ម និងបំណុលពីអាជ្ញាធរពន្ធដារដូចគ្នា។ បម្រែបម្រួលទ្រព្យសកម្មពន្ធពន្យារ ឬបំណុលពន្ធពន្យារ ត្រូវបានទទួលស្គាល់ជាផ្នែកនៃពន្ធលើប្រាក់ចំណូល ឬចំណាយនៅក្នុងរបាយការណ៍ចំណេញ ឬខាត លើកលែងតែនៅពេលដែលពន្ធទាំងនោះមានការទាក់ទងនឹងផ្នែកទាំងអស់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិតផ្សេងៗទៀត (ដូចជាការវាយតម្លៃដីឡើងវិញ) ឬមូលធនក្នុងករណីណាមួយដែលទាក់ទងនឹងពន្ធពន្យារ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិតផ្សេងៗ ឬគណនីមូលធន។

៣.៨ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

ក្រុមហ៊ុនបានចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់ខ្លួនតាមមូលដ្ឋាននៃឧបករណ៍ហិរញ្ញវត្ថុ ដោយអនុលោមតាមផ្នែកទី១១ លើមូលដ្ឋាននៃឧបករណ៍ហិរញ្ញវត្ថុ។

ឧបករណ៍ហិរញ្ញវត្ថុត្រូវបានវាស់វែងជាដំបូងតាមតម្លៃប្រតិបត្តិការ (ទាំងនេះរួមបញ្ចូលទាំងថ្លៃដើមប្រតិបត្តិការ លើកលែងតែការវាស់វែងដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដែលនឹងត្រូវបានវាស់តាមតម្លៃសមស្របតាមរយៈគណនីចំណេញ ឬខាត)។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើការរៀបចំត្រូវបានបង្កើតឡើងជាប្រតិបត្តិការហិរញ្ញវត្ថុនោះ វាត្រូវបានវាស់វែងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់នាពេលអនាគត ដោយធ្វើអប្បហារតាមអត្រាទីផ្សារដែលពាក់ព័ន្ធនឹងអត្រាការប្រាក់។

ទ្រព្យសកម្មហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ត្រូវបានវាស់វែងដំបូងតាមថ្លៃដើមប្រតិបត្តិការ។ បន្ទាប់មកទៀត ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាពដកសំវិធានធនឱនភាពតម្លៃ។

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានឈប់ទទួលស្គាល់នៅពេលដែលសិទ្ធិតាមកិច្ចសន្យាចំពោះលំហូរសាច់ប្រាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុផុតកំណត់ ឬនៅពេលដែលទ្រព្យសកម្មហិរញ្ញវត្ថុ និងរាល់ហានិភ័យចម្បង។ និងភាពជាម្ចាស់កម្មសិទ្ធិត្រូវបានផ្ទេរចេញ។

ក្នុងករណីដែលមានភស្តុតាងបានបង្ហាញថាសមតុល្យយោងនៃគណនីដែលត្រូវទទួលមិនអាចប្រមូលមកវិញបាន ការខាតបង់ឱនភាពតម្លៃត្រូវបានទទួលស្គាល់ក្នុងគណនីចំណេញ ឬខាត។

បំណុលហិរញ្ញវត្ថុ

បំណុលហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ដំបូងតាមតម្លៃប្រតិបត្តិការ។ បន្ទាប់ពីមានការទទួលស្គាល់ដំបូង បំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

បំណុលហិរញ្ញវត្ថុត្រូវបានឈប់ទទួលស្គាល់នៅពេលដែលបំណុលត្រូវបានបញ្ចប់ លុបចោល ឬផុតកំណត់សង។

៣.៩ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ និងសមតុល្យនៅក្នុងធនាគារ ប្រាក់បញ្ញើតាមតម្រូវការ និងការវិនិយោគ សាច់ប្រាក់រយៈពេលខ្លី ជាមួយនឹងកាលកំណត់រយៈពេលបីខែ ឬតិចជាងនេះ នៅពេលដែលបានទិញ ហើយងាយស្រួលក្នុងការ បំប្លែងជាសាច់ប្រាក់ជាក់លាក់ និងប្រឈមតិចចំពោះហានិភ័យនៃការផ្លាស់ប្តូរតម្លៃ និងត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុនក្នុងការ គ្រប់គ្រងនូវកិច្ចសន្យារយៈពេលខ្លីរបស់ខ្លួន។

សាច់ប្រាក់សមមូលត្រូវបានយោងតាមថ្លៃដើមបានរំលស់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

៣.១០ ប្រាក់បញ្ញើ និងប្រាក់តម្កល់តាមបទប្បញ្ញត្តិ

ប្រាក់បញ្ញើ និងប្រាក់តម្កល់ជាមួយធនាគារជាតិនៃកម្ពុជា រួមបញ្ចូលទាំងប្រាក់តម្កល់ធានាដើមទុន ត្រូវបានយោងតាមថ្លៃដើមបានរំលស់ ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ប្រាក់តម្កល់ធានាដើមទុនតំណាងឱ្យប្រាក់តម្កល់ទុនបម្រុងកាតព្វកិច្ច ហើយសាច់ប្រាក់ត្រូវបានរក្សាជាមួយធនាគារជាតិនៃកម្ពុជា ដោយអនុលោមតាមច្បាប់កម្ពុជាស្តីពីធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ។ ប្រាក់បញ្ញើតាមបទប្បញ្ញត្តិក៏មិនមែនសម្រាប់ផ្តល់ហិរញ្ញប្បទាន ដល់ប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុនឡើយ ដូច្នេះហើយ ទុនបម្រុងតាមបទប្បញ្ញត្តិនេះ មិនត្រូវបានចាត់ទុកថាជាផ្នែកមួយនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល សម្រាប់គោលបំណងនៃរបាយការណ៍លំហូរសាច់ប្រាក់ឡើយ។

ប្រាក់បញ្ញើតាមបទប្បញ្ញត្តិត្រូវបានបញ្ជាក់តាមថ្លៃដើមនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

៣.១១ ឥណទានផ្តល់ជូនអតិថិជន

ឥណទានផ្តល់ជូនអតិថិជនគឺជាទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមែនជាឧបករណ៍និស្សន្ទដែលមានកាលកំណត់ ឬការទូទាត់ថេរដែល មិនត្រូវបានដកស្រង់នៅក្នុងទីផ្សារសកម្ម ហើយក្រុមហ៊ុនពុំមានបំណងបញ្ចោញឥណទានភ្លាមៗ ឬក្នុងលក្ខខណ្ឌកំណត់ដែលមាន រយៈពេលតៀកជាងនេះ។

ឥណទានផ្តល់ជូនអតិថិជនត្រូវបានវាស់វែងដំបូងក្នុងតម្លៃសមស្រប បូកនឹងថ្លៃដើមប្រតិបត្តិការផ្ទាល់បន្ថែម ហើយត្រូវបានវាស់វែង ជាបន្តបន្ទាប់តាមថ្លៃដើមបានរំលស់ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

៣.១២ ទ្រព្យសកម្មផ្សេៗ

ទ្រព្យសកម្មផ្សេងៗ ត្រូវបានយោងតាមថ្លៃដើមរំលស់ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាព ហិរញ្ញវត្ថុ។

៣.១៣ ទ្រព្យសម្បត្តិ និងបរិក្ខារ

សមាសធាតុនៃទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់បង្គរ និងការខាតបង់លើឱនភាពតម្លៃប្រសិនបើមាន។ នៅពេលដែលផ្នែកនៃសមាសធាតុរបស់ទ្រព្យសម្បត្តិ និងបរិក្ខារមានអាយុកាលប្រើប្រាស់ខុសៗគ្នា ហើយត្រូវបានកត់ត្រាជាសមាសធាតុ ដាច់ដោយឡែក (ធាតុផ្សំចម្បងៗ) របស់ទ្រព្យសម្បត្តិ និងបរិក្ខារ។

រំលស់នៃទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានកត់ត្រានៅក្នុងគណនីចំណេញ ឬខាតលើមូលដ្ឋានរំលស់ថេរ និងរំលស់ថយចុះលើអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មដែលមានដូចខាងក្រោម៖

	អាយុកាលប្រើប្រាស់/អត្រារំលស់	**វិធីសាស្ត្រ**
ការកែលម្អទ្រព្យជួល	២០ ឆ្នាំ	រំលស់ថេរ
គ្រឿងសង្ហារិម និងគ្រឿងបំពាក់	២៥%	រំលស់ថយចុះ
បរិក្ខារការិយាល័យ	២៥%	រំលស់ថយចុះ
យានយន្ត	២៥%	រំលស់ថយចុះ
កុំព្យូទ័រ និងបរិក្ខារផ្សេងៗ	៣៣%	រំលស់ថយចុះ

ចំណាយបន្តបន្ទាប់ដែលទាក់ទងនឹងវត្ថុសមាសធាតុរបស់ទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានទទួលស្គាល់រួចរាល់ ហើយត្រូវបានបញ្ចូលទៅក្នុងសមតុល្យយោងនៃទ្រព្យសកម្ម នៅពេលដែលវាទំនងថាអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតលើសពីស្តង់ដាដែលបានវាយតម្លៃដំបូងនៃការអនុវត្តនៃទ្រព្យសកម្មដែលមានស្រាប់នឹងហូរទៅកាន់ក្រុមហ៊ុន។ រាល់ការចំណាយជាបន្តបន្ទាប់ផ្សេងៗត្រូវបានទទួលស្គាល់ជាការចំណាយក្នុងការិយបរិច្ឆេទដែលចំណាយទាំងនោះបានកើតឡើង។

ចំណេញ ឬខាតដែលកើតមានពីការផុតកំណត់ ឬការលក់ចេញនៃសមាសធាតុទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានកំណត់ដោយភាពខុសគ្នារវាងសាច់ប្រាក់សុទ្ធដែលបានពីការលក់ និងសមតុល្យយោងនៃទ្រព្យសកម្មនោះ ហើយត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាតនៅកាលបរិច្ឆេទផុតកំណត់ ឬលក់ចេញ។

សមាសធាតុនៃទ្រព្យសម្បត្តិ និងបរិក្ខារដែលបានរំលស់ពេញលេញ ត្រូវបានរក្សានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់មានការលក់ចេញ ឬលុបចោល។

៣.១៤ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី រួមមានអាជ្ញាបណ្ណកម្មវិធីកុំព្យូទ័រ ត្រូវបានកំណត់តាមថ្លៃដើមដករំលស់បង្គរ និងការខាតបង់ឱនភាពតម្លៃបង្គរ។ អាជ្ញាបណ្ណកម្មវិធីកុំព្យូទ័រត្រូវបានធ្វើមូលធនកម្មដោយផ្អែកលើមូលដ្ឋានថ្លៃដើមដែលកើតឡើងដើម្បីទទួលបានកម្មវិធីជាក់លាក់ និងយកទៅប្រើប្រាស់។

ទ្រព្យសកម្មអរូបី ត្រូវបានធ្វើរំលស់លើអាយុកាលដែលបានប៉ាន់ស្មានក្នុងរយៈពេល ១០ឆ្នាំ ដោយប្រើប្រាស់វិធីសាស្ត្ររំលស់ថេរ។ ប្រសិនបើមានការបង្ហាញថា មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅក្នុងអត្រារំលស់ អាយុកាលប្រើប្រាស់ ឬតម្លៃសំណល់នៃទ្រព្យសកម្មអរូបី នោះការរំលស់ត្រូវបានកែសម្រួលឱ្យសមស្របទៅនឹងការរំពឹងទុកថ្មី។

សមាសធាតុនៃទ្រព្យសកម្មអរូបីដែលបានរំលស់ពេញលេញ ត្រូវបានរក្សានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់ការលក់ចេញ ឬលុបចោល។

៣.១៥ ឱនភាពតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

សមតុល្យយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ក្រុមហ៊ុន (ក្រៅពីទ្រព្យសកម្មពន្ធពន្យារ) ត្រូវបានត្រួតពិនិត្យនៅកាលបរិច្ឆេទនៃរបាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានការបង្ហាញពីឱនភាពតម្លៃណាមួយដែរឬទេ។ ប្រសិនបើមានការបង្ហាញបែបនេះ សមតុល្យយោងដែលអាចទទួលបានមកវិញរបស់ទ្រព្យសកម្មត្រូវបានប៉ាន់ស្មាន។

សមតុល្យដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់គឺមានទំហំធំជាងតម្លៃប្រើប្រាស់ និងតម្លៃសមស្របដកថ្លៃដើមនៃការលក់។ ក្នុងការវាយតម្លៃលើតម្លៃប្រើប្រាស់ លំហូរសាច់ប្រាក់នាពេលអនាគតដែលបានប៉ាន់ស្មានត្រូវធ្វើអប្បហារទៅជាតម្លៃបច្ចុប្បន្ន ដោយប្រើប្រាស់អត្រាអប្បហារមុនបង់ពន្ធ ដើម្បីឱ្យសមស្របនឹងការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃពេលវេលានៃសាច់ប្រាក់ និងហានិភ័យជាក់លាក់របស់ទ្រព្យសកម្ម។ សម្រាប់គោលបំណងនៃការធ្វើតេស្តលើឱនភាពតម្លៃ ទ្រព្យសកម្មត្រូវបានចាត់ថ្នាក់ជាក្រុមតូចៗនៃទ្រព្យសកម្មដែលបានបង្កើតលំហូរចូលនៃសាច់ប្រាក់ពីការប្រើប្រាស់បន្តហើយភាគច្រើនមិនអាស្រ័យទៅលើលំហូរចូលនៃសាច់ប្រាក់របស់ទ្រព្យសកម្មផ្សេងៗ ឬក្រុមនៃទ្រព្យសកម្ម ("ឯកតាបង្កើតសាច់ប្រាក់")។

ការខាតបង់ឱនភាពតម្លៃត្រូវបានទទួលស្គាល់ប្រសិនបើសមតុល្យយោងនៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាកលើសពីសមតុល្យដែលអាចប្រមូលមកវិញបាន។ ការខាតបង់ឱនភាពតម្លៃត្រូវបានទទួលស្គាល់នៅក្នុងគណនីចំណេញ ឬខាត។

៣.១៦ គណនីត្រូវសងផ្សេងៗ

គណនីត្រូវសងផ្សេងៗ ត្រូវបានយោងតាមថ្លៃដើមរំលស់ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

៣.១៧ សំវិធានធន

សំវិធានធនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬបង្កើតនូវកាតព្វកិច្ច ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងមក ហើយវាទំនងជាថាលំហូរចេញនៃអត្ថប្រយោជន៍សេដ្ឋកិច្ចនឹងត្រូវបានទូទាត់តាមកាតព្វកិច្ច។ ប្រសិនបើផលប៉ះពាល់មានជាសារវន្ត នោះសំវិធានធនត្រូវបានកំណត់ដោយការធ្វើអប្បហារលំហូរសាច់ប្រាក់នាពេលអនាគតដែលបានរំពឹងទុកក្នុងអត្រាបង់ពន្ធមុនដើម្បីឱ្យមានភាពសមស្របនឹងការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃពេលវេលារបស់សាច់ប្រាក់ និងហានិភ័យជាក់លាក់របស់បំណុល។ ការបន្ធូរបន្ថយនៃការធ្វើអប្បហារត្រូវបានទទួលស្គាល់ជាចំណាយហិរញ្ញវត្ថុ។

៣.១៨ អត្ថប្រយោជន៍និយោជិត

អត្ថប្រយោជន៍រយៈពេលខ្លី

អត្ថប្រយោជន៍របស់និយោជិតរយៈពេលខ្លី ត្រូវបានចំណាយតាមសេវាកម្មដែលពាក់ព័ន្ធដែលត្រូវបានផ្តល់ជូន។ បំណុលក៏ត្រូវបានទទួលស្គាល់ទៅលើសមតុល្យដែលបានរំពឹងថានឹងត្រូវបានទូទាត់ ប្រសិនបើក្រុមហ៊ុនមានកាតព្វកិច្ចស្របច្បាប់ ឬបង្កើតនូវកាតព្វកិច្ចក្នុងការទូទាត់សមតុល្យនេះដែលជាលទ្ធផលនៃសេវាកម្មដែលផ្តល់កន្លងមកដោយនិយោជិត និងកាតព្វកិច្ចដែលអាចប៉ាន់ស្មានជាក់ស្តែង។

អត្ថប្រយោជន៍នៃការបញ្ចប់ការងារ

អត្ថប្រយោជន៍នៃការបញ្ចប់ការងារ គឺជាការទូទាត់សងដល់និយោជិតដែលជាលទ្ធផលនៃការបញ្ចប់ការងារមុនថ្ងៃចូលនិវត្តន៍ ឬការសម្រេចចិត្តរបស់និយោជិតក្នុងការទទួលយកការសុំឈប់ពីការងារដោយស្ម័គ្រចិត្តជាថ្នូរនឹងអត្ថប្រយោជន៍ទាំងនោះ។ អត្ថប្រយោជន៍ទាំងនោះត្រូវបានទទួលស្គាល់ជាបំណុល និងចំណាយនៅពេលដែលក្រុមហ៊ុនមានផែនការផ្លូវការលម្អិត សម្រាប់ការបញ្ចប់ការងារដោយមិនមានលទ្ធភាពនៃការដកប្រាក់ជាក់ស្តែង។ នៅក្នុងករណីនៃការសុំឈប់ពីការងារដោយស្ម័គ្រចិត្ត អត្ថប្រយោជន៍ត្រូវបានកត់ត្រាដោយផ្អែកលើចំនួនបុគ្គលិកដែលរំពឹងថានឹងទទួលយកនូវអត្ថប្រយោជន៍នេះ។

នៅពេលដែលអត្ថប្រយោជន៍នៃការបញ្ចប់ការងារដល់កាលកំណត់លើសពីរយៈពេល ១២ ខែបន្ទាប់ពីចុងការិយបរិច្ឆេទនៃរបាយការណ៍ អត្ថប្រយោជន៍ទាំងនោះត្រូវបានធ្វើអប្បហារទៅជាតម្លៃបច្ចុប្បន្នដោយផ្អែកលើទិន្នផលទីផ្សារនាចុងការិយបរិច្ឆេទនៃរបាយការណ៍។

អត្ថប្រយោជន៍និយោជិតរយៈពេលវែងផ្សេងៗ

កាតព្វកិច្ចសុទ្ធសាធរបស់ក្រុមហ៊ុនទាក់ទងនឹងអត្ថប្រយោជន៍រយៈពេលវែងរបស់និយោជិត រួមទាំងកាតព្វកិច្ចប្រាក់សំណងអតីតភាពការងារដែលជាសមតុល្យនៃអត្ថប្រយោជន៍របស់និយោជិតដែលត្រូវទទួលបានពីការបង្វិលត្រឡប់មកវិញនូវសេវាកម្មរបស់ពួកគេ នៅក្នុងការិយបរិច្ឆេទបច្ចុប្បន្ន និងមុនៗ។ អត្ថប្រយោជន៍ទាំងនោះ ត្រូវបានធ្វើអប្បហារដើម្បីកំណត់តម្លៃបច្ចុប្បន្នរបស់វា។ ការវាស់វែងឡើងវិញត្រូវបានទទួលស្គាល់នៅក្នុងគណនីចំណេញ ឬខាត នៅក្នុងការិយបរិច្ឆេទដែលការវាស់វែងទាំងនោះបានកើតឡើង។

៣.១៩ មូលធន និងប្រាក់ចំណេញរក្សាទុក

ដើមទុនតំណាងឱ្យតម្លៃចារឹកនៃភាគហ៊ុនដែលត្រូវបានបោះផ្សាយ។ ប្រាក់ចំណេញរក្សាទុករួមបញ្ចូលទាំងចំណេញ ឬខាតក្នុងការិយបរិច្ឆេទបច្ចុប្បន្ន និងមុនៗទាំងអស់។

៣.២០ ភាគលាភ

ភាគលាភត្រូវបានប្រកាស និងអនុម័តដោយភាគហ៊ុនិករបស់ក្រុមហ៊ុនមុនចុងការិយបរិច្ឆេទនៃរបាយការណ៍ ហើយត្រូវបានទទួលស្គាល់ជាបំណុល និងត្រូវបានកត់ត្រាសម្រាប់ការកាត់កងពីប្រាក់ចំណេញរក្សាទុកនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ភាគលាភដែលបានប្រកាស និងបានអនុម័តដោយភាគហ៊ុនិករបស់ក្រុមហ៊ុនបន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍មិនត្រូវបានទទួលស្គាល់ជាបំណុលនោះទេ ប៉ុន្តែត្រូវបានបង្ហាញជាព្រឹត្តិការណ៍បន្តបន្ទាប់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ថ្លៃដើមបន្ថែមដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងវិភាគទាននៃការបោះផ្សាយឧបករណ៍មូលធនត្រូវបានកាត់កងពីការវាស់វែងដំបូងនៃឧបករណ៍មូលធន។

៣.២១ ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិត្រូវបានបង្កើតឡើងពីភាពលម្អៀងនៃសំវិធានធនរវាងអ៊ីមែរមិនឥណទាន ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម និងទុនបម្រុងតាមបទប្បញ្ញត្តិដោយអនុលោមតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ៧-០១៧-៣៤៤ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ និងសារាចរលេខ ធ៧-០១៨-០០១ ស.រ.ជ.ណ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមែរមិនសម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ។

ដោយផ្អែកលើសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជាទាំងនេះ ឥណទានផ្តល់ជូនអតិថិជនទាំងអស់ត្រូវបានចាត់ថ្នាក់តាមលទ្ធភាពនៃការទូទាត់សងរបស់សមភាគី និងចំនួនថ្ងៃហួសកាលកំណត់សងដែលត្រូវបានកំណត់ដូចខាងក្រោម៖

ចំណាត់ថ្នាក់	**ចំនួនថ្ងៃហួសកាលកំណត់**	**សំវិធានធន**
ឥណទានរយៈពេលខ្លី (តិចជាង ឬស្មើនឹងមួយឆ្នាំ)		
ឥណទានធម្មតា/ឥណទានស្តង់ដា	តិចជាង ១៥ ថ្ងៃ	១%
ឥណទានឃ្លាំមើល	១៥ ថ្ងៃ – ៣០ ថ្ងៃ	៣%
ឥណទានក្រោមស្តង់ដា	៣១ ថ្ងៃ – ៦០ ថ្ងៃ	២០%
ឥណទានជាប់សង្ស័យ	៦១ ថ្ងៃ – ៩០ ថ្ងៃ	៥០%
ឥណទានបាត់បង់	ច្រើនជាង ៩១ ថ្ងៃ	១០០%
ឥណទានរយៈពេលវែង (ច្រើនជាងមួយឆ្នាំ)		
ឥណទានធម្មតា/ឥណទានស្តង់ដា	តិចជាង ៣០ ថ្ងៃ	១%
ឥណទានឃ្លាំមើល	ច្រើនជាង ៣០ – ៨៩ ថ្ងៃ	៣%
ឥណទានក្រោមស្តង់ដា	ច្រើនជាង ៩០ – ១៧៩ ថ្ងៃ	២០%
ឥណទានជាប់សង្ស័យ	ច្រើនជាង ១៨០ – ៣៥៩ ថ្ងៃ	៥០%
ឥណទានបាត់បង់	ច្រើនជាង ៣៥៩ ថ្ងៃ	១០០%

អនុលោមតាមមាត្រា ៧៣ ក្រុមហ៊ុនធ្វើការប្រៀបធៀបសំវិធានធនដែលបានគណនា ដោយអនុលោមតាមតម្រូវការខាងលើ ហើយក្រុមហ៊ុនធ្វើការកត់ត្រាស្ថិតក្រោមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម ដែលមានចែងដូចខាងក្រោម៖

១. ប្រសិនបើសំវិធានធនតាមបទប្បញ្ញត្តិទាប ក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធន ដែលត្រូវបានគណនានោះដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម និង

២. ប្រសិនបើសំវិធានធនតាមបទប្បញ្ញត្តិខ្ពស់ ក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធនដែលត្រូវបានគណនាដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូច និងមធ្យម និងផ្ទេរតម្លៃដែលលម្អៀងនោះពីគណនីប្រាក់ចំណេញរក្សាទុក ទៅក្នុងគណនីទុនបម្រុងតាមបទប្បញ្ញត្តិនៃគណនីមូលធន។

ទុនបម្រុងតាមបទប្បញ្ញត្តិមិនមែនជាសមាសធាតុដែលរួមបញ្ចូលនៅក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ក្រុមហ៊ុននោះទេ។

៣.២១ ភាគីពាក់ព័ន្ធ

ភាគីពាក់ព័ន្ធ គឺជាបុគ្គល ឬអង្គភាពដែលមានទំនាក់ទំនងជាមួយក្រុមហ៊ុន។ ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ គឺជាការផ្ទេរធនធាន សេវាកម្ម ឬកាតព្វកិច្ចរវាងក្រុមហ៊ុន និងភាគីពាក់ព័ន្ធរបស់ខ្លួនទោះបីជាបានគិតថ្លៃ ឬមិនបានគិតថ្លៃ។ សម្រាប់គោលបំណងនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ភាគីពាក់ព័ន្ធ ជាបុគ្គល ឬអង្គភាពដែលមានលក្ខណៈវិនិច្ឆ័យដូចបានរៀបរាប់ខាងក្រោមនេះ៖

ក. បុគ្គល ឬមនុស្សដែលជិតស្និទ្ធ ជាមួយបុគ្គលនៃគ្រួសារនោះ គឺមានការពាក់ព័ន្ធជាមួយក្រុមហ៊ុន ប្រសិនបើបុគ្គលនោះ
   ១. មានសិទ្ធិគ្រប់គ្រង ឬចូលរួមក្នុងការគ្រប់គ្រងលើក្រុមហ៊ុន
   ២. មានឥទ្ធិពលខ្លាំងលើក្រុមហ៊ុន ឬ
   ៣. គឺជាសមាជិកនៃគណៈគ្រប់គ្រងសំខាន់ៗរបស់ក្រុមហ៊ុន។

ខ. អង្គភាពដែលចាត់ចូលជាភាគីពាក់ព័ន្ធនៃក្រុមហ៊ុន ប្រសិនបើស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម៖
   ១ អង្គភាព និងក្រុមហ៊ុន គឺជាសមាជិកនៃសម្ព័ន្ធក្រុមហ៊ុនតែមួយ
   ២ អង្គភាពមួយដែលជាការចូលរួម ឬការបណ្តាក់ទុនរួមគ្នានៃអង្គភាពផ្សេងទៀត
   ៣ អង្គភាពទាំងពីរធ្វើការបណ្តាក់ទុនរួមលើភាគីទីបីដូចគ្នា
   ៤ អង្គភាពមួយ គឺជាភាគហ៊ុនរួមនៃអង្គភាពភាគីទីបី និងអង្គភាពផ្សេងទៀតគឺជាអង្គភាពរួមបញ្ចូលគ្នានៃភាគីទីបី
   ៥ អង្គភាព គឺជាគម្រោងអត្ថប្រយោជន៍ក្រោយបំពេញការងារសម្រាប់អត្ថប្រយោជន៍របស់និយោជិតទាំងក្រុមហ៊ុន ឬអង្គភាពដែលទាក់ទងនឹងក្រុមហ៊ុន
   ៦ អង្គភាពត្រូវបានគ្រប់គ្រង ឬគ្រប់គ្រងរួមគ្នាដោយបុគ្គលដែលបានបញ្ជាក់នៅក្នុងចំណុច ក. ខាងលើ
   ៧ បុគ្គលដែលបានកំណត់អត្តសញ្ញាណនៅក្នុងចំណុច ក. ១ ខាងលើមានឥទ្ធិពលគួរឱ្យកត់សម្គាល់លើអង្គភាព ឬជាសមាជិកនៃគណៈគ្រប់គ្រងសំខាន់ៗរបស់ក្រុមហ៊ុន ឬអង្គភាពមេចុងក្រោយ
   ៨ អង្គភាព ឬសមាជិកនៃសម្ព័ន្ធ ដែលជាផ្នែកមួយផ្តល់នូវសេវាកម្មគ្រប់គ្រងសំខាន់ៗដល់ក្រុមហ៊ុនឬជូនចំពោះក្រុមហ៊ុន។

៤. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

ក្រុមហ៊ុនបានធ្វើការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យទាក់ទងនឹងប្រតិបត្តិការនាពេលអនាគត ដែលមានភាពមិនស្មើនឹងលទ្ធផលជាក់ស្តែង។ គណនេយ្យប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យដែលអាចបណ្តាលឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើការទទួលស្គាល់និងវាស់វែងលើទ្រព្យសកម្ម បំណុល ចំណូល និងចំណាយត្រូវបានសង្ខេបដូចខាងក្រោម៖

ការប៉ាន់ស្មាន និងការសន្មតគណនេយ្យសំខាន់ៗ

ចំណូល និងពន្ធផ្សេងៗ

ពន្ធត្រូវបានគណនាដោយផ្អែកលើការបកស្រាយបច្ចុប្បន្ននៃកាតព្វកិច្ចពន្ធ។ ទោះជាយ៉ាងណាក៏ដោយ បទប្បញ្ញត្តិទាំងនេះមានការប្រែប្រួលតាមកាលកំណត់ និងការបកស្រាយផ្សេងៗគ្នា បន្ទាប់ពីមានការត្រួតពិនិត្យដោយអាជ្ញាធរពន្ធដារ។ ការត្រួតពិនិត្យទាំងនេះអាចបណ្តាលឱ្យមានការកើនឡើងពន្ធ និងការទាមទារពន្ធផ្សេងៗឡើងវិញ។ វាអាចមានផលលំបាកក្នុងការព្យាករណ៍ពីពេលវេលា និងរឹតត្បិតនៃការកើតឡើងទាំងនេះ ឬផលប៉ះពាល់ជាសក្តានុពលរបស់វា។

អាយុកាលប្រើប្រាស់ទ្រព្យសកម្មដែលអាចធ្វើវិលស់បាន

គណនេយ្យរបស់ទ្រព្យសម្បត្តិ និងបរិក្ខារពាក់ព័ន្ធនឹងការប៉ាន់ស្មានលើការប្រើប្រាស់ សម្រាប់កំណត់លើអាយុកាលដែលរំពឹងទុកនៃទ្រព្យសកម្មទាំងនេះ។ ការកំណត់នៃអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម គឺផ្អែកលើការវិនិច្ឆ័យរបស់គណៈគ្រប់គ្រង។

សំវិធានធនលើបំណុលជាប់សង្ស័យ

គណៈគ្រប់គ្រងបង្កើតសំវិធានធនចំពោះបំណុលជាប់សង្ស័យតាមមូលដ្ឋាននៃករណីនីមួយៗ នៅពេលដែលគណៈគ្រប់គ្រងជឿជាក់ថាការប្រមូលនូវសមតុល្យដែលជំពាក់អាចនឹងមិនកើតឡើង។ ក្នុងការបង្កើតសំវិធានធនទាំងនេះ គណៈគ្រប់គ្រងពិចារណាលើបទពិសោធន៍ប្រវត្តិសាស្ត្ររបស់ខ្លួន និងការផ្លាស់ប្តូរស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជនរបស់ខ្លួន។ ប្រសិនបើស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជនកាន់តែយ៉ាប់យ៉ឺន អាចបណ្តាលឱ្យអតិថិជនអសមត្ថភាពក្នុងការទូទាត់តាមតម្រូវការ នោះសំវិធានធនអាចនឹងត្រូវធ្វើឡើងសម្រាប់គណនីដែលត្រូវទទួលទាំងនោះ។

(ទំព័រនេះត្រូវបានទុកចន្លោះទំនេរដោយចេតនា)

៥. សាច់ប្រាក់ក្នុងដៃ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	(បានបញ្ជាក់ឡើងវិញ)
	ដុល្លារអាមេរិក	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២ និង២១)	
ប្រាក់រៀល	**៦៨.០៧១**	**២៧៨.០៧០**	២៩.៥២៤	១២១.៥៥០
ប្រាក់ដុល្លារអាមេរិក	**១៣.៧៦៩**	**៥៦.២៤៦**	១៤.៣១១	៥៨.៩១៩
	៨១.៨៤០	**៣៣៤.៣១៦**	៤៣.៨៣៥	១៨០.៤៦៩

៦. ប្រាក់បញ្ញើ និងប្រាក់តម្កល់ជាមួយធនាគារជាតិនៃកម្ពុជា

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២)	
ប្រាក់បញ្ញើធានាដើមទុន (*)	**១២៧.៨៨៨**	**៥២២.៤២២**	១២៧.៨៨៨	៥២៦.៥១៥
គណនីចរន្ត	**១១.៥៩៣**	**៤៧.៣៥៨**	១០.៤៣៩	៤២.៩៧៧
	១៣៩.៤៨១	**៥៦៩.៧៨០**	១៣៨.៣២៧	៥៦៩.៤៩២

(*) ប្រាក់បញ្ញើធានាដើមទុនត្រូវបានរក្សាទុកជាមួយធនាគារជាតិនៃកម្ពុជា ដោយអនុលោមតាមប្រកាសលេខ ៧-០០-០០៦ ស្តីពីការផ្តល់អាជ្ញាបណ្ណមីក្រូហិរញ្ញវត្ថុ សមតុល្យនេះត្រូវបានកំណត់ត្រឹម ៥% នៃដើមទុនដែលបានចុះបញ្ជីរបស់ក្រុមហ៊ុន។ ប្រាក់បញ្ញើធានាដើមទុនអាចបង្វិលមកវិញបាននៅពេលដែលក្រុមហ៊ុនស្ម័គ្រចិត្តរំលាយចោល ហើយមិនមានប្រាក់បញ្ញើបំណុល។

ប្រាក់បញ្ញើធានាដើមទុនទទួលបានអត្រាការប្រាក់ ០.៣៦% ក្នុងមួយឆ្នាំ។

៧. ប្រាក់បញ្ញើ និងប្រាក់តម្កល់ជាមួយធនាគារផ្សេងៗ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២)	
គណនីចរន្ត	**៣.១៥៧**	**១២.៨៩៦**	២.៣៣៩	៩.៦៣០
គណនីសន្សំ	**១.១៨១.៣០៧**	**៤.៨២៥.៦៣៩**	១.៦៩០.៩៧៦	៦.៩៦១.៧៤៨
	១.១៨៤.៤៦៤	**៤.៨៣៨.៥៣៥**	១.៦៩៣.៣១៥	៦.៩៧១.៣៧៨

ប្រាក់បញ្ញើ និងប្រាក់តម្កល់ជាមួយធនាគារផ្សេងៗត្រូវបានវិភាគដូចខាងក្រោម៖

(ក) តាមកាលកំណត់

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២)	
រយៈពេលមួយខែ	**១.១៨៤.៤៦៤**	**៤.៨៣៨.៥៣៥**	១.៦៩៣.៣១៥	៦.៩៧១.៣៧៨

(ខ) តាមអត្រាការប្រាក់ (ប្រចាំឆ្នាំ)

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២
គណនីចរន្ត	**0,00%**	0,00%
គណនីសន្សំ	**0,00%**	0,00%

៨. ឥណទានផ្តល់ជូនអតិថិជន សុទ្ធ

(បានបញ្ជាក់ឡើងវិញ)

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២ និង២១)	
ឥណទានផ្តល់ជូនអតិថិជនដុល	**២.៤៣៨.៦២១**	**៩.៩៦១.៧៦៧**	២.១៩៦.០៧៥	៩.០៤១.២៤០
ការប្រាក់ដែលត្រូវទទួល	**៣៩.៣៤៦**	**១៦០.៧២៦**	២៤.១៣១	៩៩.៣៤៨
ឥណទានផ្តល់ជូនអតិថិជនតាមថ្លៃដើមបានរំលស់	**២.៤៧៧.៩៦៧**	**១០.១២២.៤៩៣**	២.២២០.២០៦	៩.១៤០.៥៨៨
ដក៖ ចំណូលមិនទាន់បានទទួល	**(៦២.៦៣២)**	**(២៥៥.៨៥០)**	(៧០.៣១០)	(២៨៩.៤៦៦)
ដក៖ សំវិធានធនសម្រាប់ឥណទានខាតបង់	**(៤១០.៥៧១)**	**(១.៦៧៧.១៨២)**	(២៣៨.៣១០)	(៩៨១.១២២)
ឥណទានផ្តល់ជូនអតិថិជន-សុទ្ធ	**២.០០៤.៧៦៤**	**៨.១៨៩.៤៦១**	១.៩១១.៥៨៦	៧.៨៧០.០០០

បម្រែបម្រួលសំវិធានធនសម្រាប់ការខាតបង់ឥណទានមានដូចខាងក្រោម៖

(បានបញ្ជាក់ឡើងវិញ)

	ឆ្នាំ២០២៣		ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២ និង២១)	
នាថ្ងៃទី១ ខែមករា	**២៣៨.៣១០**	**៩៨១.១២២**	១៨៤.៣៦៣	៧៥១.០៩៥
សំវិធានធនក្នុងការិយបរិច្ឆេទ	**៣៤១.២៤៥**	**១.៤០២.៥១៧**	១៩៥.៧៥៦	៨០០.០៥៥
ការលុបចោលពីបញ្ជីក្នុងការិយបរិច្ឆេទ	**(១៦៨.៩៨៤)**	**(៦៩៤.៥២៣)**	(១៤១.៨០៩)	(៥៧៩.៥៧៣)
លម្អៀងពីការប្តូររូបិយប័ណ្ណ	**-**	**(១១.៩៣៤)**	-	៩.៥៤៥
នាថ្ងៃទី៣១ ខែធ្នូ	**៤១០.៥៧១**	**១.៦៧៧.១៨២**	២៣៨.៣១០	៩៨១.១២២

ឥណទានដុលផ្តល់ជូនអតិជនត្រូវបានវិភាគដូចខាងក្រោម៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		(បានបញ្ជាក់ឡើងវិញ) ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២ និង២១)	
តាមកាលកំណត់៖				
រយៈពេលមួយខែ	**១៨២.៥៣៣**	**៥៨២.២៤៨**	២៧.៤០៤	១១២.៨២៨
រយៈពេល១ ទៅ ៣ ខែ	**៨២.៤២៧**	**៣៣៦.៧១៥**	៨៤.១០២	៣៤៦.២៤៦
រយៈពេល៣ ទៅ ១២ ខែ	**១.០៦៤.៦៣៧**	**៤.៣៤៩.០៤១**	១.៣៨៩.៦៨៥	៥.៧២១.៣៣១
រយៈពេលលើសពី ១២ ខែ	**១.១៤៩.០២៤**	**៤.៦៩៣.៧៦៣**	៦៩៤.៨៨៤	២.៨៦០.៨៣៥
	២.៤៣៨.៦២១	**៩.៩៦១.៧៦៧**	២.១៩៦.០៧៥	៩.០៤១.២៤០
តាមប្រភេទរូបិយប័ណ្ណ៖				
ប្រាក់ដុល្លារអាមេរិក	**៣៤៧.៣០២**	**៨.៥៤៣.០៣៨**	១៣៤.៦៩៦	៥៥៤.៥៤១
ប្រាក់រៀល	**២.០៩១.៣១៩**	**១.៤១៨.៧២៩**	២.០៦១.៣៧៩	៨.៤៨៦.៦៩៩
	២.៤៣៨.៦២១	**៩.៩៦១.៧៦៧**	២.១៩៦.០៧៥	៩.០៤១.២៤០
តាមស្ថានភាព៖				
និវាសនជន	**២.៤៣៨.៦២១**	**៩.៩៦១.៧៦៧**	២.១៩៦.០៧៥	៩.០៤១.២៤០
តាមទំនាក់ទំនង៖				
អតិថិជនខាងក្រៅ	**២.៣៩៥.៥៧៨**	**៩.៧៨៥.៩៣៧**	២.១៩៥.១៨១	៩.០៣៧.៣៩៥
ឥណទាននិយោជិត	**៨៣.០៨៣**	**១៧៥.៨៣០**	៩៣៨	៣.៨៨៥
	២.៤៣៨.៦២១	**៩.៩៦១.៧៦៧**	២.១៩៦.០៧៥	៩.០៤១.២៤០
តាមផ្នែកសេដ្ឋកិច្ច៖				
ឧស្សាហកម្ម	**១.២២៧.៨៣៧**	**៥.០១៥.៧១១**	១.១៨២.៣០៨	៤.៧០២.៨៨៣
កសិកម្ម	**៥៨៤.២៧៧**	**២.២២៣.៣៧២**	៥២៩.៥១៧	២.១៨០.០២២
ពាណិជ្ជកម្ម	**៨១៥.៨៨៣**	**១.៦៩៨.៧២០**	៣៧៦.៩៩៧	១.៥៥២.០៩៥
សេវាកម្ម	**២៣៨.៥១៩**	**៩៥៨.០០៩**	១៣២.៨៥២	៥៨៦.៩៥២
សំណង់	**១២.៦៥៥**	**៥១.៦៩៧**	១៣.២៧៨	៥៨.៦៨៩
ដឹកជញ្ជូន	**១.៦៩៥**	**៦.៩២៥**	-	-
ផ្សេងៗ	**១.៧៩៥**	**៧.៣៣៣**	១.១២៧	៨.៦៣៩
	២.៤៣៨.៦២១	**៩.៩៦១.៧៦៧**	២.១៩៦.០៧៥	៩.០៤១.២៤០

មិនមានទ្រព្យធានា	**១.៦២៥.៣៧៥**	**៦.៦៣៩.៦៥៧**	៨៩៤.៤៣៤	៣.៦៨២.៣៨៣
មានទ្រព្យធានា	**៨១៣.២៤៦**	**៣.៣២២.១១០**	១.៣០១.៦៤១	៥.៣៥៨.៨៥៧
	២.៤៣៨.៦២១	**៩.៩៦១.៧៦៧**	២.១៩៦.០៧៥	៩.០៤១.២៤០

តាមអត្រាការប្រាក់ (ប្រចាំឆ្នាំ)៖

ឥណទានជាក្រុម	**១៨,០០%**	១៨,០០%
ឥណទានបុគ្គល	**១៨,០០%**	១៨,០០%

៩. ទ្រព្យសកម្មផ្សេងៗ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២)	
ចំណាយបង់មុន	**១០១.២៣២**	**៤១៣.៥៣៣**	១១១.៦២២	៤៥៩.៥៤៨
ប្រាក់បញ្ញើ	**៤៨.៨០០**	**១៩៩.៣៤៨**	៤៩.៨០៥	២០៥.០៤៧
	១៥០.០៣២	**៦១២.៨៨១**	១៦១.៤២៧	៦៦៤.៥៩៥

(ទំព័រនេះត្រូវបានទុកចន្លោះទំនេរដោយចេតនា)

១០. ទ្រព្យសម្បត្តិ និងបរិក្ខារ

	ការកែលម្អ ទ្រព្យជួល ដុល្លារអាមេរិក	គ្រឿងសង្ហារិមនិង គ្រឿងបំពាក់ ដុល្លារអាមេរិក	បរិក្ខារ ការិយាល័យ ដុល្លារអាមេរិក	ម៉ូតូ* ដុល្លារអាមេរិក	កុំព្យូទ័រ និង បរិក្ខារផ្សេងៗ ដុល្លារអាមេរិក	ដុល្លារអាមេរិក	សរុប ពាន់រៀល (កំណត់សម្គាល់ ៣.២)
ថ្លៃដើម							
សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២៣	១៨៩.៩០១	៣៥.៧៥៣	៧២.៧៦០	៤៥.១២០	១០៦.៩៤៧	៤៥០.៤៨១	១.៨៥៤.៦៣១
ទិញបន្ថែម	-	-	២.៤១០	-	២.៤៤០	៤.៨៥០	១៩.៩៣១
លុបចោល	-	-	(៤១០)	-	(៤.១០៨)	(៤.៥១៨)	(១៨.៥៦៩)
ជម្រះចេញពីបញ្ជី	-	-	-	-	(១.៥៥៧)	(១.៥៥៧)	(៦.៣៩៩)
លម្អៀងពីការប្តូរប្រាក់	-	-	-	-	-	-	(១៤.៣៨៥)
សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣	១៨៩.៩០១	៣៥.៧៥៣	៧៤.៧៦០	៤៥.១២០	១០៣.៧២២	៤៤៩.២៥៦	១.៨៣៥.២០៩
រំលស់បង្គរ							
សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២៣	១១៤.៥៥៦	៣២.៥៤៣	៦១.៩៨៨	៤៤.៧២០	៨៨.៤៨០	៣៤២.២៨៧	១.៤០៩.១៩៦
រំលស់	២៨.៥៨៤	៩៩២	៤.១៣៧	២០០	៧.១៨០	៤១.០៩៣	១៦៨.៨៩២
លុបចោល	-	-	(៤១០)	-	(៤.១០៨)	(៤.៥១៨)	(១៨.៥៦៩)
ជម្រះចេញពីបញ្ជី	-	-	-	-	(៩៤៧)	(៩៤៧)	(៣.៨៩២)
លម្អៀងពីការប្តូរប្រាក់	-	-	-	-	-	-	(១១.៨៤៦)
សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣	១៤៣.១៤០	៣៣.៥៣៥	៦៥.៧១៥	៤៤.៩២០	៩០.៦០៥	៣៧៧.៩១៥	១.៥៤៣.៧៨១
សមតុល្យយោងគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣	៤៦.៧៦១	២.២១៨	៩.០៤៥	២០០	១៣.១១៧	៧១.៣៤១	២៩១.៤២៨

*នៅដំណាច់ការិយបរិច្ឆេទដែលបានបញ្ចាប់ កម្មសិទ្ធិម៉ូតូដែលមានតម្លៃចុះបញ្ជីសុទ្ធក្នុងសមតុល្យ ២០០ ដុល្លារអាមេរិក ត្រូវបានចុះបញ្ជីក្រោមនាមរបស់ភាគីទីបីមួយចំនួន។ ទោះជាយ៉ាងណាក៏ដោយ កម្មសិទ្ធិម៉ូតូរបស់ក្រុមហ៊ុនត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងកិច្ចព្រមព្រៀងទិញរវាងក្រុមហ៊ុន និងភាគីទីបី។

	ការកែលម្អ ទ្រព្យជួល ដុល្លារអាមេរិក	គ្រឿងសង្ហារិមនិង គ្រឿងបំពាក់ ដុល្លារអាមេរិក	បរិក្ខារ ការិយាល័យ ដុល្លារអាមេរិក	ម៉ូតូ ដុល្លារអាមេរិក	កុំព្យូទ័រ និង បរិក្ខារផ្សេងៗ ដុល្លារអាមេរិក	ដុល្លារអាមេរិក	សរុប ពាន់រៀល
							(កំណត់សម្គាល់ ៣.២)
ថ្លៃដើម							
សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២២	១៧០.២៧០	៣២.៥០៥	៦៩.៤១៩	៨៦.៥៩៥	៩០.៩២២	៤០៩.៧១១	១.៦៦៩.១៦៣
ទិញបន្ថែម	១៩.៦៣១	៣.៥៨៣	៧.៤២២	៣០០	១៨.០១១	៤៨.៩៤៧	២០០.០៤៦
លុបចោល	-	(៣៣៥)	(៤.០៨១)	(១.៧៧៥)	(១.៩៨៦)	(៨.១៧៧)	(៣៣.៤១៩)
លម្អៀងពីការប្តូរប្រាក់	-	-	-	-	-	-	១៨.៨៤១
សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	១៨៩.៩០១	៣៥.៧៥៣	៧២.៧៦០	៤៥.១២០	១០៦.៩៤៧	៤៥០.៤៨១	១.៨៥៤.៦៣១
រំលស់បង្គរ							
សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២២	៨៦.៥៥៩	៣២.២៩៦	៦២.៩៣៣	៤៦.២២០	៨៤.៧៥៧	៣១២.៧៦៥	១.២៧៤.២០៥
រំលស់	២៧.៩៩៧	៥៨២	៣.១៣៦	២៧៥	៥.៧០៩	៣៧.៦៩៩	១៥៤.០៧៦
លុបចោល	-	(៣៣៥)	(៤.០៨១)	(១.៧៧៥)	(១.៩៨៦)	(៨.១៧៧)	(៣៣.៤១៩)
លម្អៀងពីការប្តូរប្រាក់	-	-	-	-	-	-	១៤.៣៣៤
សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	១១៤.៥៥៦	៣២.៥៤៣	៦១.៩៨៨	៤៤.៧២០	៨៨.៤៨០	៣៤២.២៨៧	១.៤០៩.១៩៦
សមតុល្យយោងគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	៧៥.៣៨៥	៣.២១០	១០.៧៧២	៤០០	១៨.៤៦៧	១០៨.១៩៤	៤៤៥.៤៣៥

១១. គណនីត្រូវសងផ្សេងៗ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២)	
សំវិធានធនលើអត្ថប្រយោជន៍និយោជិត (*)	**៦០.២៥៨**	**២៤៦.១៥៤**	-	-
ចំណាយបង្គរ	**១៧.៤១៣**	**៧១.១៣២**	២០.០៨៤	៨២.៦៨៦
ពន្ធកាត់ទុកដែលត្រូវសង	**៤.៦៦០**	**១៩.០៣៦**	៤.១១៣	១៦.៩៣៣
បុព្វលាភបង្គរ និងចំណាយដែលពាក់ព័ន្ធ	**៧៦៧**	**៣.១៣៣**	៥២.៨៦៩	២១៧.៦៦២
ពន្ធត្រូវសងផ្សេងៗ	**១១២**	**៤៥៨**	-	-
ផ្សេងៗ	**១៣.៤៥៥**	**៥៤.៩៦៤**	១៣.៣២៨	៥៤.៨៧១
	៩៦.៦៦៥	**៣៩៤.៨៧៧**	៩០.៣៩៤	៣៧២.១៥២

(*) គណនីនេះតំណាងឱ្យសំវិធានធនលើប្រាក់បំណាច់អតីតភាពការងារដែលតម្រូវតាមប្រកាសលេខ ៤៤៣ បានចេញផ្សាយដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (“MoLVT”) ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ហើយបន្ទាប់មកត្រូវបានធ្វើវិសោធនកម្ម តាមប្រកាសលេខ ០៤២/១៩ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩។ តាមប្រកាសនេះ មានការទាមទារឱ្យនិយោជកទាំងអស់ត្រូវទូទាត់ប្រាក់សំណងបំណាច់អតីតភាពការងារដល់និយោជិតរបស់ពួកគេដូចខាងក្រោម៖

ការទូទាត់បច្ចុប្បន្ន៖ ចាប់ពីឆ្នាំ២០១៩ តទៅ ក្នុងសមតុល្យស្មើនឹង ១៥ ថ្ងៃនៃប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងទៀតក្នុងមួយឆ្នាំ។

ប្រាក់រំលឹកបំណាច់អតីតភាពការងារ (ប្រាក់រំលឹក)៖ ចាប់ពីឆ្នាំ២០២១ តទៅ ក្នុងសមតុល្យស្មើនឹង ៦ ថ្ងៃនៃប្រាក់ឈ្នួលសុទ្ធក្នុងមួយឆ្នាំ។ សំវិធានធនលើប្រាក់រំលឹកបំណាច់អតីតភាពការងារត្រូវបានគណនាក្នុងរយៈពេល ៦ ថ្ងៃ នៃប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗក្នុងមួយឆ្នាំលើសមតុល្យជាអតិបរមានៃប្រាក់ឈ្នួលសុទ្ធរយៈពេល ៦ ខែ (អាស្រ័យលើរយៈពេលនៃបុគ្គលិកបម្រើសេវាកម្ម) រហូតដល់និយោជិតដែលមានប្រាក់បំណាច់អតីតភាពមុនឆ្នាំ២០១៩។

ការទូទាត់នឹងត្រូវធ្វើឡើងចំនួនពីរដងក្នុងមួយឆ្នាំ គឺរៀងរាល់ខែមិថុនា និងខែធ្នូ។ និយោជិតមិនមានសិទ្ធិទទួលបានប្រាក់បំណាច់អតីតភាពការងារដែលនៅសេសសល់ដែលមិនទាន់ដល់កំណត់ទេ ប្រសិនបើគាត់/នាងលាលែងពីអង្គភាព។

បម្រែបម្រួលសំវិធានធនលើអត្ថប្រយោជន៍និយោជិតក្នុងអំឡុងការិយបរិច្ឆេទមានដូចខាងក្រោម៖

	ឆ្នាំ២០២៣		ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២)	
នាថ្ងៃទី១ ខែមករា	-	-	៩២.៣៥៥	៣៧៦.២៥៤
បានទទួលស្គាល់នៅក្នុងចំណេញ ឬខាត	**១១៤.៤៨៥**	**៤៧០.៥៣៥**	(៩.៩៤៥)	(៤០.៦៤៥)
បានបង់ក្នុងអំឡុងការិយបរិច្ឆេទ	**(៥៤.២២៧)**	**(២២២.៨៧២)**	(៨២.៤១០)	(៣៣៦.៨១០)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	**(១.៥០៩)**	-	១.២០១
នាថ្ងៃទី៣១ ខែធ្នូ	**៦០.២៥៨**	**២៤៦.១៥៤**	-	-

១២. ពន្ធលើប្រាក់ចំណូល

៥ (ឥណទាន)/ចំណាយពន្ធលើប្រាក់ចំណូល

អនុលោមតាមបទប្បញ្ញត្តិពន្ធរបស់ប្រទេសកម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណូលក្នុងអត្រា ២០% នៃប្រាក់ចំណូលជាប់ពន្ធ ឬពន្ធអប្បបរមាចំនួន ១% នៃចំណូលប្រចាំឆ្នាំ រួមទាំងពន្ធទាំងអស់ លើកលែងតែពន្ធលើតម្លៃបន្ថែមដោយកំណត់យកពន្ធណាមួយដែលខ្ពស់ជាង។

(ឥណទាន)/ចំណាយពន្ធលើប្រាក់ចំណូលសម្រាប់ការិយបរិច្ឆេទត្រូវបានសង្ខេបដូចខាងក្រោម៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២)	
ចំណាយពន្ធអប្បបរមា	**១៧.៥៧១**	**៧២.២១៩**	១៩.៧៩០	៨០.៨៨២
សំវិធានធនលើសក្នុងការិយបរិច្ឆេទមុន	**-**	**-**	(៣.៩៣៥)	(១៦.០៨២)
ពន្ធពន្យារ	**(៨១.៩២១)**	**(៣៣៦.៦៩៨)**	(១២.១៨០)	(៤៩.៧៨០)
(ឥណទាន)/ចំណាយពន្ធលើប្រាក់ចំណូល	**(៦៤.៣៥០)**	**(២៦៤.៤៧៩)**	៣.៦៧៥	១៥.០២០

លិខិតប្រកាសពន្ធរបស់ក្រុមហ៊ុនត្រូវឆ្លងកាត់ការត្រួតពិនិត្យដោយអគ្គនាយកដ្ឋានពន្ធដារ។ ដោយសារតែការអនុវត្តច្បាប់ពន្ធ និងបទប្បញ្ញត្តិលើប្រតិបត្តិការជាច្រើនប្រភេទដែលមានការបង្ហាញពីសមតុល្យខុសៗគ្នា សមតុល្យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុអាចត្រូវបានផ្លាស់ប្តូរនៅពេលក្រោយតាមការកំណត់ចុងក្រោយដោយអគ្គនាយកដ្ឋានពន្ធដារ។

ការផ្ទៀងផ្ទាត់រវាង(ខាត)/ចំណេញមុនពន្ធលើប្រាក់ចំណូល និងការប៉ាន់ស្មានចំណូលជាប់ពន្ធមានដូចខាងក្រោម៖

ការផ្ទៀងផ្ទាត់រវាង(ខាត)/ចំណេញគណនេយ្យមុនពន្ធលើប្រាក់ចំណូល និងការប៉ាន់ស្មានចំណូលជាប់ពន្ធសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ត្រូវបានបង្ហាញដូចខាងក្រោម៖

(បានបញ្ជាក់ឡើងវិញ)

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២ និង២១)	
(ខាត)/ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល	**(៤១៣.៣៥២)**	**(១.៦៩៨.៨៧៦)**	៣៧.៦៩២	១៥៤.០៤៧
ចំណាយមិនអាចកាត់កងបាន	**៧៥.២១០**	**៣០៩.១១២**	៧០៧	២.៨៨៩
(ខាត)/ចំណេញជាប់ពន្ធដែលបានប៉ាន់ស្មាន	**(៣៣៨.១៤២)**	**(១.៣៨៩.៧៦៤)**	៣៨.៣៩៩	១៥៦.៩៣៦
ពន្ធលើប្រាក់ចំណូលតាមអត្រា ២០% (ក)	**(៦៧.៦២៨)**	**(២៧៧.៩៥៣)**	៧.៦៨០	៣១.៣៨៧
ពន្ធអប្បបរមាក្នុងអត្រា ១% នៃចំណូល (ខ)	**១៧.៥៧១**	**៧២.២១៩**	១៩.៧៩០	៨០.៨៨២
ចំណាយពន្ធលើប្រាក់ចំណូលបច្ចុប្បន្នដែលបានប៉ាន់ស្មាន (មួយណាដែលខ្ពស់ជាងរវាង ក និងខ)	**១៧.៥៧១**	**៧២.២១៩**	១៩.៧៩០	៨០.៨៨២

ខ. ពន្ធយថាហេតុ

ប្រព័ន្ធពន្ធដារនៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានបែងចែកជាច្រើនប្រភេទ និងបទប្បញ្ញត្តិមានការផ្លាស់ប្តូរញឹកញាប់ដែលជាធម្មតាពឹងផ្អែកលើការបកស្រាយ។ ជាញឹកញាប់ ការបកស្រាយខុសៗគ្នាជាច្រើនកើតមានឡើងក្នុងចំណោមអាជ្ញាធរពន្ធដារ និងយុត្តាធិការ។ ពន្ធដារ គឺជាកម្មវត្ថុនៃការពិនិត្យ និងការសង្កេតដោយភ្នាក់ងារពន្ធដារផ្សេងៗជាច្រើន ដែលមានសមត្ថកិច្ចក្នុងការដាក់ពិន័យធ្ងន់ធ្ងរ និងពិន័យជាការប្រាក់។

កត្តាទាំងនេះហើយដែលអាចធ្វើឱ្យមានហានិភ័យពន្ធដារនៅក្នុងព្រះរាជាណាចក្រកម្ពុជាខ្លាំងជាងប្រទេសដទៃទៀត។ គណៈគ្រប់គ្រងមានការជឿជាក់ថា ខ្លួនបានបង់បំណុលពន្ធគ្រប់គ្រាន់ដោយផ្អែកលើការបកស្រាយបទប្បញ្ញត្តិពន្ធបច្ចុប្បន្នរបស់ខ្លួន។ ទោះបីយ៉ាងនេះក្តី សមត្ថកិច្ចពន្ធពាក់ព័ន្ធអាចការបកស្រាយខុសៗគ្នា ហើយផលប៉ះពាល់អាចមានជាសារវន្ត។

គ. ទ្រព្យសកម្មពន្ធពន្យារសុទ្ធ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២)	
ទ្រព្យសកម្មពន្ធពន្យារ	**១២៣.២២៣**	**៥០៣.៣៦៦**	**៤៣.១២០**	**១៧៧.៥២៥**
បំណុលពន្ធពន្យារ	**-**	**-**	**(១.៨១៨)**	**(៧.៤៨៥)**
	១២៣.២២៣	**៥០៣.៣៦៦**	**៤១.៣០២**	**១៧០.០៤០**

ទ្រព្យសកម្មពន្ធពន្យារត្រូវបានបែងចែកដូចខាងក្រោម៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២)	
រំលស់ពន្លឿន	**១.១៣០**	**៤.៦១៦**	(១.៨១៨)	(៧.៤៨៥)
សំវិធានធនលើការខាតបង់ឥនភាពតម្លៃ	**៤៣.៨៤៤**	**១៧៩.១០៣**	២៣.៥១២	៩៦.៧៩៩
បម្រែបម្រួលចំណេញ ឬខាតដែលមិនបានទទួលស្គាល់	**២.១៩១**	**៨.៩៥០**	៤.៩៦១	២០.៤២៤
សំវិធានធនលើបុព្វលាភ និងប្រាក់បំណាច់អតីតការងារ	**៩.៣៧០**	**៣៨.២៧៦**	១៤.៦៤៧	៦០.៣០២
ប្រាក់ចំណូលដែលមិនទាន់ទទួលបាន	**១២.៥២៧**	**៥១.១៧៣**	-	-
ការខាតបង់អាជីវកម្ម	**៥៤.១៦១**	**២២១.២៤៨**	-	-
	១២៣.២២៣	**៥០៣.៣៦៦**	៤១.៣០២	១៧០.០៤០

បម្រែបម្រួលទ្រព្យសកម្មពន្ធពន្យារមានដូចខាងក្រោម៖

	សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល (កំណត់សម្គាល់ ៣.២)**	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ៣.២)
សមតុល្យនាថ្ងៃទី១ ខែមករា	**៤១.៣០២**	**១៧០.០៤០**	២៩.១២២	១១៨.៦៤៣
ការទទួលស្គាល់នៅក្នុងចំណេញ ឬខាត	**៨១.៩២១**	**៣៣៦.៦៩៨**	១២.១៨០	៤៩.៧៨០
លម្អៀងពីការប្តូររូបិយប័ណ្ណ	**-**	**(៣.៣៧២)**	-	១.៦១៧
សមតុល្យនាថ្ងៃទី៣១ ខែធ្នូ	**១២៣.២២៣**	**៥០៣.៣៦៦**	៤១.៣០២	១៧០.០៤០

ឃ. បំណុលពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល (កំណត់សម្គាល់ ៣.២)**	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ៣.២)
នាថ្ងៃទី១ ខែមករា	**១.៦៣១**	**៦.៧១៥**	៨.៣៨១	៣៤.១៤៤
ពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន	**១៧.៥៧១**	**៧២.២១៩**	១៩.៧៩០	៨០.៨៨២
ពន្ធលើប្រាក់ចំណូលដែលបានបង់	**(១៧.៦៨១)**	**(៧២.៦៦៩)**	(២២.៦០៥)	(៩២.៣៨៧)
សំវិធានធនលើសពីការិយបរិច្ឆេទមុន	**-**	**-**	(៣.៩៣៥)	(១៦.០៨២)
លម្អៀងពីការប្តូររូបិយប័ណ្ណ	**-**	**(៥២)**	-	១៥៨
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ	**១.៥២១**	**៦.២១៣**	១.៦៣១	៦.៧១៥

១៣. ដើមទុន

ក្រុមហ៊ុនមានដើមទុនចុះបញ្ជីមានសមតុល្យ ១០.២៣១.០៦០.០០០ រៀល (ឬស្មើនឹង ២.៥៥៧.៧៦៥ ដុល្លារអាមេរិក) ដែលមានតម្លៃចារឹក ១ ដុល្លារអាមេរិកក្នុងមួយហ៊ុន។ ភាគហ៊ុនទាំងអស់របស់ក្រុមហ៊ុនត្រូវបានចេញផ្សាយ និងបានទូទាត់រួចរាល់ពេញលេញ។

	% ភាគហ៊ុនកាន់កាប់	**ចំនួនភាគហ៊ុន**	**ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**		% ភាគហ៊ុនកាន់កាប់	ចំនួនភាគហ៊ុន	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
			ដុល្លារអាមេរិក	**ពាន់រៀល (កំណត់សម្គាល់ ៣.២)**			ដុល្លារអាមេរិក	ដុល្លារអាមេរិក (កំណត់សម្គាល់ ៣.២)
លោក ឈុន ស្រ៊ា	**៧៤,៩៧%**	**១.៩១៧.៥៩៦**	**១.៩១៧.៥៩៦**	**៧.៦៧០.៣៨៤**	៦៤,១៩%	១.៦៤១.៨៧៥	១.៦៤១.៨៧៥	៦.៥៦៧.៥០០
លោក ឈុន ស៊ីណា	**២៥,០៣%**	**៦៤០.១៦៩**	**៦៤០.១៦៩**	**២.៥៦០.៦៧៦**	២១,៤៣%	៥៤៨.១២២	៥៤៨.១២២	២.១៩២.៤៨៨
អ្នកស្រី ឈុន វ៉ាន់ណុច	**0,00%**	**-**	**-**	**-**	៧,៩0%	២0២.0៨៦	២0២.0៨៦	៨0៨.៣៤៤
អ្នកស្រី ឈុន វ៉ាន់ណាល់	**0,00%**	**-**	**-**	**-**	៦,៤៨%	១៦៥.៦៨២	១៦៥.៦៨២	៦៦២.៧២៨
	១00%	**២.៥៥៧.៧៦៥**	**២.៥៥៧.៧៦៥**	**១0.២៣១.0៦0**	១00%	២.៥៥៧.៧៦៥	២.៥៥៧.៧៦៥	១0.២៣១.0៦0

១៤. ចំណូលការប្រាក់

	សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		(បានបញ្ជាក់ឡើងវិញ) សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២ និង២១)	
តណាទានផ្តល់ជូនអតិថិជន	**៤៦២.០៥៥**	**១.៨៩៩.០៤៦**	៤២៣.៨២៨	១.៧៣២.១៨៥
ប្រាក់តម្កល់ធានាដើមទុន	**១.១៧៤**	**៤.៨២៥**	៧៧	៣១៥
	៤៦៣.២២៩	**១.៩០៣.៨៧១**	៤២៣.៩០៥	១.៧៣២.៥០០

១៥. ចំណូលកម្រៃសេវា និងកម្រៃជើងសា

	សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		(បានបញ្ជាក់ឡើងវិញ) សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២ និង២១)	
សេវារដ្ឋបាល	**១.២១០.៦៩៨**	**៤.៩៧៥.៩៦៨**	១.៣៦៤.១៥៤	៥.៥៧៥.២៩៧
សេវារៀបចំហិរញ្ញប្បទានឡើងវិញ	**៤.៦៤១**	**១៩.០៧៥**	៨.៨០៥	៣៥.៩៨៦
សេវាតណាទានមិនមានទ្រព្យធានាបញ្ចាំ	**៣៦៩**	**១.៥១៧**	១.៤០៦	៥.៧៤៦
ចំណូលកម្រៃសេវា និងកម្រៃជើងសា	-	-	១២៨.៣៦៨	៥២៤.៦៤០
ផ្សេងៗ	-	-	៣.៧៨៣	១៥.៤៦២
	១.២១៥.៧០៨	**៤.៩៩៦.៥៦០**	១.៥០៦.៥១៦	៦.១៥៧.១៣១

១៦. ចំណូលប្រតិបត្តិការផ្សេងៗ

	សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		(បានបញ្ជាក់ឡើងវិញ) សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២ និង២១)	
តណាទានរៀបចំឡើងវិញ	**៥២.១៤៨**	**២១៤.៣២៨**	៣៣.៧០៤	១៣៧.៧៤៨
ប្រាក់ពិន័យ	**៤៣.៧១៨**	**១៧៩.៦៨១**	៤៤.៨៤២	១៨៣.២៦៩
ផ្សេងៗ	**៣.១៤២**	**១២.៩១៤**	៤.១២៦	១៦.៨៦៣
	៩៩.០០៨	**៤០៦.៩២៣**	៨២.៦៧២	៣៣៧.៨៨០

១៧. ចំណាយទូទៅ និងចំណាយរដ្ឋបាល

	សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		(បានបញ្ហាក់ឡើងវិញ) សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល (កំណត់សម្គាល់ ៣.២)**	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ៣.២ និង២១)
ប្រាក់បៀវត្ស និងអត្ថប្រយោជន៍របស់និយោជិត	**១.២៨២.១៨២**	**៥.២៦៩.៧៦៨**	១.២០៣.៦៨៦	៤.៩១៩.៤៦៥
ការជួល	**២៤១.៤៧៦**	**៩៩២.៤៦៦**	២៣៤.៨៨៦	៩៥៩.៩៧៩
ចំណាយលើម៉ូតូសម្រាប់ប្រតិបត្តិការ	**៦៧.៨៩០**	**២៧៩.០២៨**	៧០.២០៣	២៨៦.៩២០
ការធ្វើដំណើរ	**៤២.២៩៦**	**១៧៣.៨៣៧**	៣៩.០៦២	១៥៩.៦៤៦
ទឹកភ្លើង	**៣៤.២២៣**	**១៤០.៦៥៧**	៣៣.៣៥៨	១៣៦.៣៣៤
ទំនាក់ទំនង	**៣៣.០៧៣**	**១៣៥.៩៣០**	៣២.១៣៥	១៣១.៣៣៦
សេវាច្បាប់ និងសេវាវិជ្ជាជីវៈ	**៣១.៩៦១**	**១៣១.៣៦០**	៣៣.៤៧៥	១៣៦.៨១២
សម្ភារការិយាល័យ	**១០.២៩០**	**៤២.២៩២**	១១.៨០៨	៤៨.២៥៩
ជួសជុល និងថែទាំ	**៤.៣៦៩**	**១៧.៩៥៧**	៧.១៩៣	២៩.៣៩៨
ទីផ្សារ និងការផ្សាយពាណិជ្ជកម្ម	**២.៧៦៦**	**១១.៣៦៨**	៤.៤៩២	១៨.៣៥៩
ខាតពីការលក់ចេញទ្រព្យសម្បត្តិ និងបរិក្ខារ	**៣៨២**	**១.៥៧០**	-	-
ផ្សេងៗ	**៥៨.០៥១**	**២៣៨.៥៨៨**	៧១.៦៤៨	២៩២.៨២៥
	១.៨០៨.៩៥៩	**៧.៤៣៤.៨២១**	១.៧៤១.៩៤៦	៧.១១៩.៣៣៣

១៨. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

	សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		(បានបញ្ហាក់ឡើងវិញ) សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល (កំណត់សម្គាល់ ៣.២)**	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ ៣.២ និង២១)
សាច់ប្រាក់ក្នុងដៃ (កំណត់សម្គាល់លេខ ៥)	**៨១.៨៤០**	**៣៣៤.៣១៦**	៤៣.៨៣៥	១៨០.៤៦៩
ប្រាក់បញ្ញើ និងប្រាក់តម្កល់ជាមួយធនាគារជាតិនៃកម្ពុជា (កំណត់សម្គាល់លេខ ៦)	**១១.៥៩៣**	**៤៧.៣៥៨**	១០.៤៣៩	៤២.៩៧៧
ប្រាក់បញ្ញើ និងប្រាក់តម្កល់ជាមួយធនាគារផ្សេងៗ (ជាមួយកាលកំណត់រយៈពេល ៣ខែ ឬតិចជាងនេះ) (កំណត់សម្គាល់លេខ ៧)	**១.១៨៤.៤៦៤**	**៤.៨៣៨.៥៣៥**	១.៦៩៣.៣១៥	៦.៩៧១.៣៧៨
	១.២៧៧.៨៩៧	**៥.២២០.២០៩**	១.៧៤៧.៥៨៩	៧.១៩៤.៨២៤

១៩. ភាគីពាក់ព័ន្ធ

អត្តសញ្ញាណរបស់ភាគីពាក់ព័ន្ធ

ភាគីពាក់ព័ន្ធ និងទំនាក់ទំនងជាមួយក្រុមហ៊ុនមានដូចខាងក្រោម៖

ទំនាក់ទំនង	**ភាគីពាក់ព័ន្ធ**
ភាគហ៊ុនិក	លោក ឈុន ស្រ៊ា
	លោក ឈុន ស៊ីណា
គណៈគ្រប់គ្រងសំខាន់ៗ	ក្រុមប្រឹក្សាភិបាលទាំងអស់របស់ក្រុមហ៊ុន ដែលធ្វើការសម្រេចចិត្តសំខាន់ៗទាក់ទងនឹងទិសដៅយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន និងបុគ្គលិកគណៈគ្រប់គ្រងជាន់ខ្ពស់ (រួមទាំងសមាជិកគ្រួសារជិតស្និទ្ធិ)

សមតុល្យជាមួយភាគីពាក់ព័ន្ធ

ក្រុមហ៊ុនមិនមានសមតុល្យជាមួយភាគីពាក់ព័ន្ធដែលនៅជំពាក់នោះទេ។

ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ

(១) ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២)	
ការជួលការិយាល័យ	**២៩.៣៣៣**	**១២០.៥៦០**	២៩.៣៣៣	១១៩.៨៨៥

(២) សំណងរបស់គណៈគ្រប់គ្រងសំខាន់ៗ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២)	
ប្រាក់បៀវត្ស និងអត្ថប្រយោជន៍	**៣៦.៩៧៨**	**១៥១.៩៨០**	៣៥.១១៧	១៤៣.៥២៥

២០ កិច្ចសន្យាភតិសន្យា

ក្រុមហ៊ុនមានកិច្ចសន្យាភតិសន្យាទីស្នាក់ការកណ្តាល និងសាខាការិយាល័យរបស់ខ្លួនក្រោមការរៀបចំកិច្ចព្រមព្រៀងភតិសន្យាប្រតិបត្តិការជាមួយនឹងភតិសន្យាអប្បបរមានាពេលអនាគតដែលសមតុល្យដូចបានកំណត់ខាងក្រោម៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២)	
រយៈពេល ១ឆ្នាំ	**១៨៥.២២២**	**៧៥៦.៦៣២**	២០.០០០	៨២.៣៤០
រយៈពេល ២ឆ្នាំ ទៅ ៥ឆ្នាំ	**២២៧.១១១**	**៩២៧.៧៤៨**	៥៦.៦៦៦	២៣៣.២៩៤
	៤១២.៣៣៣	**១.៦៨៤.៣៨០**	៧៦.៦៦៦	៣១៥.៦៣៤

២១. ព័ត៌មានប្រៀបធៀប

ព័ត៌មានជាក់លាក់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ត្រូវបានបញ្ជាក់ដើម្បីកែតម្រូវនូវកំហុសឆ្គងឆ្នាំមុន ត្រូវបានសង្ខេបដូចខាងក្រោម។

(១) ក្រុមហ៊ុនមិនបានកត់ត្រានូវហ្វាស៊ីលីធីនៃការប្រមូលឥណទានតាមរយៈភ្នាក់ងារ។
(២) ក្រុមហ៊ុនបានធ្វើការកត់ត្រាមិនត្រឹមត្រូវនូវសំវិធានធនឥណទាន ការនាំឱ្យមានការកត់ត្រាខុសនូវសំវិធានធនឱនភាពតម្លៃ និងការខាតបង់។
(៣) ក្រុមហ៊ុនបានកត់ត្រាមិនត្រឹមត្រូវនូវសមតុល្យនៃចំណូលការប្រាក់ និងចំណូលកម្រៃសេវា និងកម្រៃជើងសា។
(៤) ក្រុមហ៊ុនបានកត់ត្រាមិនត្រឹមត្រូវនូវភាពលម្អៀងពីការខាតបង់នៃការប្តូររូបិយប័ណ្ណបរទេស។

កំហុសឆ្គងត្រូវបានកែតម្រូវដោយធ្វើការបញ្ជាក់ឡើងវិញនូវខ្លង់នៃរបាយការណ៍ហិរញ្ញវត្ថុដែលមានផលប៉ះពាល់ក្នុងការិយបរិច្ឆេទមុន។

ស្ថានភាពរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (បានដកស្រង់)

	ដូចបានរាយការណ៍ពីមុន ដុល្លារអាមេរិក	ផលប៉ះពាល់ពីការបញ្ជាក់ឡើងវិញ ដុល្លារអាមេរិក		**(បានបញ្ជាក់ឡើងវិញ) ដុល្លារអាមេរិក**	**ពាន់រៀល**
				(កំណត់សម្គាល់ ៣.២)	
សាច់ប្រាក់ក្នុងដៃ	៣៩.៦២១	៤.២១៤	(១)	**៤៣.៨៣៥**	**១៨០.៤៦៩**
ឥណទានផ្តល់ជូនអតិថិជនសុទ្ធ	១.៩២៧.៦៨១	(១៦.០៩៥)	(២)	**១.៩១១.៥៨៦**	**៧.៨៧០.០០០**
ប្រាក់ចំណេញរក្សាទុក	១.៤៦០.០៧៧	(១១.៨៨១)	(២) (៣)	**១.៤៤៨.១៩៦**	**៥.៨៦៧.០៤៥**

របាយការណ៍ចំណូលលម្អិតគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (បានដកស្រង់)

	(ដូចបានរាយការណ៍ពីមុន) ដុល្លារអាមេរិក	ផលប៉ះពាល់ពីការបញ្ជាក់ឡើងវិញ ដុល្លារអាមេរិក		**(បានបញ្ជាក់ឡើងវិញ) ដុល្លារអាមេរិក**	**ពាន់រៀល (កំណត់សម្គាល់ ៣.២)**
ចំណូលការប្រាក់	៤០៨.៧៤៧	១៥.១៥៨	(៣)	**៤២៣.៩០៥**	**១.៧៣២.៥០០**
ចំណូកម្រៃសេវា និងកម្រៃជើងសា	១.៤៨៧.០៦៦	១៩.៤៥០	(៣)	**១.៥០៦.៥១៦**	**៦.១៥៧.១៣១**
ចំណូលប្រតិបត្តិការផ្សេងៗ	៨២.៦៦៩	៣	(៣)	**៨២.៦៧២**	**៣៣៧.៨៨០**
ចំណាយទូទៅ និងចំណាយរដ្ឋបាល	(១.៧៤៣.០២០)	១.០៧៤	(៤)	**(១.៧៤១.៩៤៦)**	**(៧.១១៩.៣៣៣)**
ការខាតបង់ឱនភាពតម្លៃសុទ្ធលើទ្រព្យសកម្មហិរញ្ញវត្ថុ	(១៤៨.១៩០)	(៤៧.៥៦៦)	(២)	**(១៩៥.៧៥៦)**	**(៨០០.០៥៥)**

របាយការណ៍បម្រែបម្រួលមូលធនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (ដកស្រង់)

	(ដូចបានរាយការណ៍ពីមុន) ដុល្លារអាមេរិក	ផលប៉ះពាល់ពីការបញ្ជាក់ឡើងវិញ ដុល្លារអាមេរិក		**(បានបញ្ជាក់ឡើងវិញ) ដុល្លារអាមេរិក**	**ពាន់រៀល (កំណត់សម្គាល់ ៣.២)**
ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ	៤៥.៨៩៨	(១១.៨៨១)	(២) (៣) (៤)	**៣៤.០១៧**	**១៣៩.០២៧**

របាយការណ៍លំហូរសាច់ប្រាក់គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (ដកស្រង់)

	(ដូចបានរាយការណ៍ពីមុន) ដុល្លារអាមេរិក	ផលប៉ះពាល់ពីការបញ្ជាក់ឡើងវិញ ដុល្លារអាមេរិក		**(បានបញ្ជាក់ឡើងវិញ) ដុល្លារអាមេរិក**	**ពាន់រៀល (កំណត់សម្គាល់ ៣.២)**
ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល	៤៥.៨៩៨	(៨.២០៦)	(២) (៣) (៤)	**៣៧.៦៩២**	**១៥៤.០៤៧**
ការខាតបង់ឱនភាពតម្លៃលើទ្រព្យសកម្មហិរញ្ញវត្ថុ	១៤៨.១៩០	៤៧.៥៦៦	(២)	**១៩៥.៧៥៦**	**៨០០.០៥៥**
ឥណទានផ្តល់ជូនអតិថិជន	(៥៧.៦៨៧)	២.២៣៣	(២)	**(៥៥.៤៥៤)**	**(២២៦.៦៤០)**

២២ ចំណាត់ថ្នាក់នៃឧបករណ៍ហិរញ្ញវត្ថុ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	**ពាន់រៀល**	ដុល្លារអាមេរិក	ពាន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២)	
ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់				
សាច់ប្រាក់ និងសាច់ប្រាក់សមមូល	**១.២៧៧.៨៩៧**	**៥.២២០.២០៩**	១.៧៤៧.៥៨៩	៧.១៩៤.៨២៤
តណាទានផ្តល់ជូនអតិថិជនសុទ្ធ	**២.០០៤.៧៦៤**	**៨.១៨៩.៤៦១**	១.៩១១.៥៨៦	៧.៨៧០.០០០
ទ្រព្យសកម្មផ្សេងៗ(*)	**៤៨.៨០០**	**១៩៩.៣៤៨**	៤៩.៨០៥	២០៥.០៤៧
	៣.៣៣១.៤៦១	**១៣.៦០៩.០១៨**	៣.៧០៨.៩៨០	១៥.២៦៩.៨៧១

**មិនរួមបញ្ចូលចំណាយបង់មុន*

បំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់				
បំណុលផ្សេងៗ*	**៩១.៨៩៣**	**៣៧៥.៣៨៣**	៨៦.២៨១	៣៥៥.២១៩
ស្ថានភាពទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ	**៩១.៨៩៣**	**៣៧៥.៣៨៣**	៨៦.២៨១	៣៥៥.២១៩

**មិនរួមបញ្ចូលពន្ធកាត់ទុក និងបំណុលពន្ធត្រូវសងផ្សេងៗ*

ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

គោលការណ៍ណែនាំ និងគោលនយោបាយដែលបានអនុវត្តដោយក្រុមហ៊ុនដើម្បីចាត់ចែងនូវហានិភ័យដែលកើតឡើងក្នុងសកម្មភាពអាជីវកម្មមានដូចខាងក្រោម៖

ក. ហានិភ័យតណាទាន

ហានិភ័យតណាទាន គឺជាការខាតបង់ចំណូល និងការខាតបង់ប្រាក់ដើមនៅក្នុងទម្រង់នៃសំវិធានធនជាក់លាក់ដែលជាលទ្ធផលពីការខកខានពីអ្នកខ្ចី ឬសមភាគីតាមរយៈសកម្មភាពផ្តល់ប្រាក់កម្ចី និងសកម្មភាពការវិនិយោគ។ ការប្រឈមចម្បងទៅនឹងហានិភ័យតណាទានកើតឡើងតាមរយៈតណាទានផ្តល់ជូនអតិថិជន។ សមតុល្យនៃការប្រឈមនូវផលប៉ះពាល់តណាទានក្នុងន័យនេះ តំណាងដោយសមតុល្យយោងនៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ សកម្មភាពផ្តល់ប្រាក់កម្ចីត្រូវបានណែនាំដោយគោលនយោបាយតណាទានរបស់ក្រុមហ៊ុន ដើម្បីធានាថាគោលបំណងទូទៅក្នុងការឱ្យខ្ចីបានសម្រេចជោគជ័យ ឧទាហរណ៍ សំពៀតតណាទានមានភាពរឹងមាំ និងមានគុណភាពល្អ ហើយហានិភ័យតណាទានត្រូវបានធ្វើពិពិធកម្ម។ គោលនយោបាយតណាទាន កត់ត្រានូវគោលនយោបាយផ្តល់ប្រាក់កម្ចី គោលនយោបាយវត្ថុបញ្ចាំ និងនីតិវិធីនៃការអនុម័តតណាទានដែលបានអនុវត្តដើម្បីធានាបាននូវការអនុលោមតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

ក្រុមហ៊ុនកាន់កាប់វត្ថុបញ្ចាំដែលតណាទានផ្តល់ជូនអតិថិជនក្នុងទម្រង់ការប្រាក់នៃវត្ថុបញ្ចាំរបស់ទ្រព្យសម្បត្តិ និងការធានា។ ការប៉ាន់ស្មានតម្លៃសមស្របផ្អែកលើតម្លៃវត្ថុបញ្ចាំដែលបានវាយតម្លៃនៅពេលខ្ចី ហើយជាទូទៅមិនត្រូវបានធ្វើបច្ចុប្បន្នភាពទេ លើកលែងតែនៅពេលដែលប្រាក់កម្ចីត្រូវបានវាយតម្លៃជាលក្ខណៈបុគ្គលថាមានការសង្ស័យ។

១. ការវាស់វែងហានិភ័យឥណទាន

ក្រុមហ៊ុន វាយតម្លៃនូវប្រូបាប៊ីលីតេនៃការខកខានរបស់សមភាគីនីមួយៗ តាមរយៈការព្យាករណ៍លើស្ថានភាពប្រាក់ចំណេញ និងលំហូរសាច់ប្រាក់របស់អ្នកខ្ចី។ គណៈកម្មការឥណទាន ជាអ្នកទទួលខុសត្រូវក្នុងការអនុម័តលើឥណទានផ្តល់ជូនអតិថិជន។

២. កម្រិតនៃការត្រួតពិនិត្យហានិភ័យ និងគោលនយោបាយកាត់បន្ថយ

ក្រុមហ៊ុនគ្រប់គ្រងកម្រិត និងត្រួតពិនិត្យការប្រមូលផ្តុំហានិភ័យឥណទាននៅពេលដែលវាត្រូវបានកំណត់អត្តសញ្ញាណ។

ក្រុមហ៊ុនបានប្រើប្រាស់គោលនយោបាយ និងការអនុវត្តជាច្រើន ដើម្បីកាត់បន្ថយហានិភ័យឥណទាន។ ជាទូទៅ ទម្រង់នៃវត្ថុបញ្ចាំទាំងនេះសម្រាប់ឥណទានផ្តល់ជូនអតិថិជន វាគឺជាការអនុវត្តទូទៅ។ ក្រុមហ៊ុនបានអនុវត្តសេចក្តីណែនាំស្តីពីការទទួលយកការធ្វើចំណាត់ថ្នាក់នៃវត្ថុបញ្ចាំ ឬការកាត់បន្ថយហានិភ័យឥណទាន។ ប្រភេទនៃវត្ថុបញ្ចាំសំខាន់ៗដែលក្រុមហ៊ុនទទួលយកដើម្បីធានាឥណទានផ្តល់ជូនអតិថិជនមានដូចខាងក្រោម៖

- បញ្ចាំលើទ្រព្យសម្បត្តិនៃលំនៅដ្ឋាន (ដី អគារ និងអចលនទ្រព្យផ្សេងទៀត) និង
- ចំណាយលើទ្រព្យសកម្មរបស់អាជីវកម្ម ដូចជាដី និងអគារ។

៣. ការប្រឈមនឹងហានិភ័យឥណទានទាក់ទងនឹងឥណទានផ្តល់ជូនអតិថិជន

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២	
	ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
	(កំណត់សម្គាល់ ៣.២)		(កំណត់សម្គាល់ ៣.២)	
ឥណទានផ្តល់ជូនអតិថិជន- ដុល				
មិនទាន់ហួសកាលកំណត់ និងមានឱនភាពតម្លៃ	**២.០៦០.០៤៨**	**៨.៤១៥.២៩៦**	១.៩៣៣.៣៩៨	៧.៩៥៩.៨០២
ហួសកាលកំណត់ ប៉ុន្តែមិនមានឱនភាពតម្លៃ	**២៤៧.២៣៣**	**១.០០៩.៩៤៦**	២១៨.០០៦	៨៩៧.៥៣០
ឱនភាពនៃតម្លៃដាច់ដោយឡែក	**១៣១.៣៤០**	**៥៣៦.៥២៥**	៤៤.៦៧១	១៨៣.៩០៨
	២.៤៣៨.៦២១	**៩.៩៦១.៧៦៧**	២.១៩៦.០៧៥	៩.០៤១.២៤០

មិនទាន់ហួសកាលកំណត់ និងមានឱនភាពតម្លៃ

មិនទាន់ហួសកាលកំណត់ និងមានឱនភាពតម្លៃលើឥណទានផ្តល់ជូនអតិថិជនគឺជាឥណទានផ្តល់ជូនអតិថិជនដែលមានគុណភាពល្អ ហើយមិនដែលមានបទពិសោធន៍ខកខានក្នុងការទូទាត់ទេ។ ឥណទានទាំងនេះ ត្រូវបានគាំទ្រដោយទ្រព្យធានាបញ្ចាំ និងគណៈគ្រប់គ្រងមើលឃើញថាលទ្ធភាពនៃការខកខានក្នុងការទូទាត់ គឺមានការប្រឈមទាប។

ហួសកាលកំណត់ ប៉ុន្តែមិនមានឱនភាពតម្លៃ

ហួសកាលកំណត់ ប៉ុន្តែមិនមានឱនភាពតម្លៃឥណទានផ្តល់ជូនអតិថិជន ដែលមានការប្រាក់ ឬការទូទាត់ប្រាក់ដើមតាមកិច្ចសន្យាត្រូវហួសកំណត់សងតិចជាង ៣០ ថ្ងៃសម្រាប់ឥណទានរយៈពេលខ្លី និង ៩០ ថ្ងៃសម្រាប់ឥណទានរយៈពេលវែង លើកលែងតែមានព័ត៌មានផ្សេងទៀតដែលចង្អុលបង្ហាញផ្សេងទៀត។

ឱនភាពតម្លៃឥណទាន

ឱនភាពតម្លៃឥណទានដាច់ដោយឡែកនៃឥណទានផ្តល់ជូនអតិថិជន គឺជាឥណទានដែលក្រុមហ៊ុនកំណត់ថាមានភស្តុតាងជាក់លាក់នៃឱនភាពតម្លៃហើយវាមិនរំពឹងថានឹងប្រមូលមកវិញនូវប្រាក់ដើម និងការប្រាក់ទាំងអស់ ដោយសារតែលក្ខខណ្ឌនៃកិច្ចសន្យាលើឥណទានផ្តល់ជូនអតិថិជន។

អនុលោមតាមសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា សំវិធានធនលើឥណទានផ្តល់ជូនអតិថិជនជាប់សង្ស័យត្រូវបានធ្វើឡើងសម្រាប់ឥណទានផ្តល់ជូនអតិថិជនមានការទូទាត់ហួសកាលកំណត់លើសពីរយៈពេល ៣០ ថ្ងៃសម្រាប់ឥណទានរយៈពេលខ្លី និងរយៈពេល ៨៩ ថ្ងៃសម្រាប់ឥណទានរយៈពេលវែង។ កម្រិតអប្បបរមានៃសំវិធានធនជាក់លាក់លើឱនភាពតម្លៃត្រូវបានធ្វើឡើងអាស្រ័យលើចំណាត់ថ្នាក់ដែលពាក់ព័ន្ធ លុះត្រាតែមានព័ត៌មានផ្សេងទៀតដើម្បីបញ្ជាក់ពីសមត្ថភាពនៃការទូទាត់សងរបស់សមភាគី។

ក. ហានិភ័យប្រតិបត្តិការ

ការខាតបង់ដែលបណ្តាលមកពីហានិភ័យប្រតិបត្តិការដែលជាលទ្ធផលពីកង្វះខាត ឬការបរាជ័យក្នុងដំណើរការផ្ទៃក្នុង ធនធានមនុស្ស និងប្រព័ន្ធ ឬបណ្តាលមកពីកត្តាខាងក្រៅ គឺត្រូវបានគ្រប់គ្រងតាមរយៈការបង្កើតដំណើរការគ្រប់គ្រងហានិភ័យប្រតិបត្តិការ ការត្រួតពិនិត្យ និងការរាយការណ៍ឱ្យបានត្រឹមត្រូវពីសកម្មភាពអាជីវកម្ម ដោយត្រួតពិនិត្យ និងគាំទ្រដល់អង្គភាពដែលមានឯករាជ្យភាពពីអង្គភាពអាជីវកម្ម និងការត្រួតពិនិត្យដែលធ្វើឡើងដោយគណៈគ្រប់គ្រង។

ការគ្រប់គ្រងលើហានិភ័យប្រតិបត្តិការ តម្រូវឱ្យមានការបង្កើតនូវរចនាសម្ព័ន្ធ តួនាទី និងគោលនយោបាយក្នុងការត្រួតពិនិត្យយ៉ាងច្បាស់លាស់មួយ។ គោលនយោបាយ និងវិធានការត្រួតពិនិត្យផ្ទៃក្នុងនីមួយៗ ត្រូវបានអនុវត្ត។ វិធានការទាំងនេះរួមមានការបង្កើតនូវសិទ្ធិអំណាចក្នុងការចុះហត្ថលេខា ការកំណត់ប្រព័ន្ធត្រួតពិនិត្យ ការរៀបចំនូវនីតិវិធី រួមទាំងចងក្រងឯកសារ។ វិធានការទាំងនេះ ត្រូវបានត្រួតពិនិត្យជាបន្តបន្ទាប់ដើម្បីឆ្លើយតបទៅនឹងហានិភ័យប្រតិបត្តិការអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ។

ខ. ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារ គឺជាហានិភ័យនៃការខាតបង់ដែលកើតឡើងពីការប្រែប្រួលអវិជ្ជមាននៅក្នុងកម្រិតតម្លៃ ឬអត្រាទីផ្សារដែលមានសមាសធាតុសំខាន់ពីរ គឺហានិភ័យរូបិយប័ណ្ណបរទេស និងហានិភ័យអត្រាការប្រាក់។

១. ហានិភ័យការប្តូររូបិយប័ណ្ណបរទេស

ប្រាក់ចំណូលរបស់ក្រុមហ៊ុនគឺទទួលបានជាចម្បងជាប្រាក់ដុល្លារអាមេរិក។ ការចំណាយរបស់ក្រុមហ៊ុនជាចម្បងគឺបានទូទាត់ជាប្រាក់ដុល្លារអាមេរិក។ ទ្រព្យសកម្ម និងបំណុលរូបិយវត្ថុ ត្រូវបានគ្របដណ្តប់ជាចម្បងទៅលើប្រាក់ដុល្លារអាមេរិក។ ដូច្នេះ ក្រុមហ៊ុនមិនមានការប្រឈមពីការប៉ះពាល់ជាចម្បងទៅលើហានិភ័យរូបិយប័ណ្ណបរទេសនោះទេ។

២. ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ គឺសំដៅទៅលើអស្ថេរភាពនៃចំណូលការប្រាក់សុទ្ធ ដែលជាលទ្ធផលពីការប្រែប្រួលនូវកម្រិតអត្រាការប្រាក់ និងការផ្លាស់ប្តូរសមាសភាពរបស់ទ្រព្យសកម្ម និងបំណុល។ ការកើតឡើងនូវហានិភ័យអត្រាការប្រាក់ពាក់ព័ន្ធជាចម្បងជាមួយនឹងឥណទាន។

ដោយសារតែទ្រព្យសកម្មហិរញ្ញវត្ថុភាគច្រើនមិនមានការផ្លាស់ប្តូរដែលគួរឱ្យកត់សម្គាល់ជាមួយអត្រាទីផ្សារ ក្រុមហ៊ុនមិនបានប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ ដើម្បីការពារហានិភ័យនេះទេ។

តារាងខាងក្រោមសង្ខេបហានិភ័យនៃអត្រាការប្រាក់របស់ក្រុមហ៊ុន។ វារួមបញ្ចូលទាំងឧបករណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនក្នុងសមតុល្យយោង ការចាត់ថ្នាក់ឡើងវិញដោយកំណត់តម្លៃតាមកិច្ចសន្យា ឬកាលបរិច្ឆេទផុតកំណត់។

ឆ្នាំ២០២៣	រហូតដល់១ ខែ ជុំល្លារអាមេរិក	ពី ១ – ៣ ខែ ជុំល្លារអាមេរិក	ពី ៣ – ១២ ខែ ជុំល្លារអាមេរិក	ពី ១ - ៥ ឆ្នាំ ជុំល្លារអាមេរិក	លើសពី ៥ឆ្នាំ ជុំល្លារអាមេរិក	មិនមានការប្រាក់ ជុំល្លារអាមេរិក	សរុប ជុំល្លារអាមេរិក	អត្រាការប្រាក់ %
ទ្រព្យសកម្មហិរញ្ញវត្ថុ								
សាច់ប្រាក់ និងសាច់ប្រាក់សមមូល	១.១៩៦.០៥៧	-	-	-	-	៨១.៨៤០	១.២៧៧.៨៩៧	មិនមាន
ឥណទានផ្តល់ជូនអតិថិជនដុល	១៣៧.៣៦៩	៨៥.០០៩	១.០៦៧.២១៩	១.១៤៣.៣៥៨	៥.៦៦៦	-	២.៤៣៨.៦២១	១៨%
ទ្រព្យសកម្មផ្សេងៗ*	-	-	-	-	-	៤៨.៨០០	៤៨.៨០០	មិនមាន
ទ្រព្យសកម្មហិរញ្ញវត្ថុសរុប	១.៣៣៣.៤២៦	៨៥.០០៩	១.០៦៧.២១៩	១.១៤៣.៣៥៨	៥.៦៦៦	១៣០.៦៤០	៣.៧៦៥.៣១៨	
បំណុលហិរញ្ញវត្ថុ								
បំណុលផ្សេងៗ**	-	-	-	-	-	៩១.៨៩៣	៩១.៨៩៣	មិនមាន
បំណុលហិរញ្ញវត្ថុសរុប	-	-	-	-	-	៩១.៨៩៣	៩១.៨៩៣	
គម្លាតតម្លៃការប្រាក់សរុប	១.៣៣៣.៤២៦	៨៥.៩០៩	១.០៦៧.២១៩	១.១៤៣.៣៥៨	៥.៦៦៦	៣៨.៧៤៧	៣.៦៧៣.៤២៥	
សមមូលជាពាន់រៀល (កំណត់សម្គាល់លេខ ៣.២)	៥.៤៤៧.០៤៦	៣៤៧.២៦៣	៤.៣៥៩.៥៨៩	៤.៦៧០.៦១៦	២៣.១៤៨	១៥៨.២៨១	១៥.០០៥.៩៤៣	

** មិនរួមបញ្ចូលចំណាយបង់មុន*

** *មិនរួមបញ្ចូលពន្ធកាត់ទុក និងបំណុលពន្ធត្រូវសងផ្សេងៗ*

ឆ្នាំ២០២២	រហូតដល់១ ខែ ដុល្លារអាមេរិក	ពី ១ – ៣ ខែ ដុល្លារអាមេរិក	ពី ៣ – ១២ ខែ ដុល្លារអាមេរិក	ពី ១ - ៥ ឆ្នាំ ដុល្លារអាមេរិក	លើសពី ៥ឆ្នាំ ដុល្លារអាមេរិក	មិនមានការប្រាក់ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក	អត្រាការប្រាក់ %
ទ្រព្យសកម្មហិរញ្ញវត្ថុ								
សាច់ប្រាក់ និងសាច់ប្រាក់សមមូល	១.៧០៣.៧៥៨	-	-	-	-	៤៣.៨៣៥	១.៧៤៧.៥៨៩	មិនមាន
ឥណទានផ្តល់ជូនអតិថិជនដុល	២៧.៤០៨	៨៤.១០២	១.៣៨៩.៦៨៥	៦៩៤.៨៨៤	-	-	២.១៩៦.០៧៥	១៨%
ទ្រព្យសកម្មផ្សេងៗ*	-	-	-	-	-	៤៩.៨០៥	៤៩.៨០៥	មិនមាន
ទ្រព្យសកម្មហិរញ្ញវត្ថុសរុប	១.៧៣១.១៥៨	៨៤.១០២	១.៣៨៩.៦៨៥	៦៩៤.៨៨៤	-	៩៣.៦៤០	៣.៩៩៣.៤៦៩	
បំណុលហិរញ្ញវត្ថុ								
បំណុលផ្សេងៗ**	-	-	-	-	-	៨៦.២៨១	៨៦.២៨១	មិនមាន
បំណុលហិរញ្ញវត្ថុសរុប	-	-	-	-	-	៨៦.២៨១	៨៦.២៨១	
គម្លាតតម្លៃការប្រាក់សរុប	១.៧៣១.១៥៨	៨៤.១០២	១.៣៨៩.៦៨៥	៦៩៤.៨៨៤	-	៧.៣៥៩	៣.៩០៧.១៨៨	
សមមូលជាពាន់រៀល (កំណត់សម្គាល់លេខ ៣.២)	៧.១២៧.១៧៩	៣៤៦.២៤៦	៥.៧២១.៣៣១	២.៨៦០.៨៣៦	-	៣០.២៩៧	១៦.០៨៥.៨៨៩	

** មិនរួមបញ្ចូលចំណាយបង់មុន*

***មិនរួមបញ្ចូលពន្ធកាត់ទុក និងបំណុលពន្ធត្រូវសងផ្សេងៗ*

គ ហានិភ័យសាច់ប្រាក់ងាយស្រួល

ហានិភ័យសាច់ប្រាក់ងាយស្រួល ទាក់ទងនឹងលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការរក្សាទ្រព្យសកម្មជាសាច់ប្រាក់ងាយស្រួលឱ្យបានគ្រប់គ្រាន់ដើម្បីបំពេញតាមកិច្ចសន្យាហិរញ្ញវត្ថុ និងកាតព្វកិច្ចនៅពេលដល់ពេលកំណត់សង តាមតម្លៃសមស្រប។

បន្ថែមពីលើការអនុលោមពេញលេញនៃហានិភ័យសាច់ប្រាក់ងាយស្រួល គណៈគ្រប់គ្រងរបស់ក្រុមហ៊ុនបានធ្វើការត្រួតពិនិត្យយ៉ាងហ្មត់ចត់លើលំហូរសាច់ប្រាក់ចេញចូល និងការព្យាករណ៍លំហូរសាច់ប្រាក់ទៅតាមការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗទៅធនាគារជាតិនៃកម្ពុជា។ បម្រែបម្រួលឥណទាន និងប្រាក់បញ្ញើពីអតិថិជន ត្រូវបានត្រួតពិនិត្យនិងធ្វើការកែតម្រូវដើម្បីធានាបាននូវទ្រព្យសកម្មសាច់ប្រាក់ងាយស្រួលឱ្យបានគ្រប់គ្រាន់ដើម្បីបំពេញតាមកិច្ចសន្យាហិរញ្ញវត្ថុ និងតាមកាតព្វកិច្ចនៅពេលដល់កាលកំណត់សង។

តារាងខាងក្រោមផ្តល់នូវការវិភាគលើទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទៅក្នុងក្រុមដែលពាក់ព័ន្ធដល់កាលកំណត់ រួមទាំងការកំណត់បង់រំលស់។

ឆ្នាំ២០២៣	រហូតដល់១ ខែ ដុល្លារអាមេរិក	ពី ១ – ៣ ខែ ដុល្លារអាមេរិក	ពី ៣ – ១២ ខែ ដុល្លារអាមេរិក	ពី ១ - ៥ ឆ្នាំ ដុល្លារអាមេរិក	លើសពី ៥ឆ្នាំ ដុល្លារអាមេរិក	មិនមានកាលកំណត់សងជាក់លាក់ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
ទ្រព្យសកម្មហិរញ្ញវត្ថុ							
សាច់ប្រាក់ និងសាច់ប្រាក់សមមូល	១.២៧៧.៨៩៧	-	-	-	-	-	១.២៧៧.៨៩៧
តណាទានផ្តល់ជូនអតិថិជនដុល	១៣៧.៣៦៩	៨៥.០០៩	១.០៦៧.២១៩	១.១៤៣.៣៥៨	៥.៦៦៦	-	២.៤៣៨.៦២១
ទ្រព្យសកម្មផ្សេងៗ*	-	-	-	២៤.៨០០	២៤.០០០	-	៤៨.៨០០
ទ្រព្យសកម្មហិរញ្ញវត្ថុសរុប	១.៤១៥.២៦៦	៨៥.០០៩	១.០៦៧.២១៩	១.១៦៨.១៥៨	២៩.៦៦៦	-	៣.៧៦៥.៣១៨
បំណុលហិរញ្ញវត្ថុ							
បំណុលផ្សេងៗ**	៩១.៨៩៣	-	-	-	-	-	៩១.៨៩៣
បំណុលហិរញ្ញវត្ថុសរុប	៩១.៨៩៣	-	-	-	-	-	៩១.៨៩៣
អតិរេកសាច់ប្រាក់ងាយស្រួលសុទ្ធ	១.៣២៣.៣៧៣	៨៥.០០៩	១.០៦៧.២១៩	១.១៦៨.១៥៨	២៩.៦៦៦	-	៣.៦៧៣.៤២៥
សមមូលជាពាន់រៀល (កំណត់សម្គាល់លេខ ៣.២)	៥.៤០៥.៩៧៩	៣៤៧.២៦៣	៤.៣៥៩.៥៨៩	៤.៧៧១.៩២៣	១២១.១៨៨	-	១៥.០០៥.៩៤៣

** មិនរាប់បញ្ចូលចំណាយបង់មុន*

*** មិនរាប់បញ្ចូលពន្ធកាត់ទុក និងពន្ធត្រូវបង់ផ្សេងៗ*

ឆ្នាំ២០២២	រហូតដល់១ ខែ ដុល្លារអាមេរិក	ពី ១ – ៣ ខែ ដុល្លារអាមេរិក	ពី ៣ – ១២ ខែ ដុល្លារអាមេរិក	ពី ១ - ៥ ឆ្នាំ ដុល្លារអាមេរិក	លើសពី ៥ឆ្នាំ ដុល្លារអាមេរិក	មិនមានកាលកំណត់សងជាក់លាក់ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
ទ្រព្យសកម្មហិរញ្ញវត្ថុ							
សាច់ប្រាក់ និងសាច់ប្រាក់សមមូល	១.៧៤៧.៥៨៩	-	-	-	-	-	១.៧៤៧.៥៨៩
ឥណទានផ្តល់ជូនអតិថិជនដុល	២៧.៤០៤	៨៤.១០២	១.៣៨៩.៦៨៥	៦៩៤.៨៨៤	-	-	២.១៩៦.០៧៥
ទ្រព្យសកម្មផ្សេងៗ*	-	-	-	៤៩.៨០៥	-	-	៤៩.៨០៥
ទ្រព្យសកម្មហិរញ្ញវត្ថុសរុប	១.៧៧៤.៩៩៣	៨៤.១០២	១.៣៨៩.៦៨៥	៧៤៤.៦៨៩	-	-	៣.៩៩៣.៤៦៩
បំណុលហិរញ្ញវត្ថុ							
ប្រាក់កម្ចី	-	-	-	-	-	-	-
បំណុលផ្សេងៗ**	៨៦.២៨១	-	-	-	-	-	៨៦.២៨១
បំណុលហិរញ្ញវត្ថុសរុប	៨៦.២៨១	-	-	-	-	-	៨៦.២៨១
អតិរេកសាច់ប្រាក់ងាយស្រួលសុទ្ធ	១.៦៨៨.៧១២	៨៤.១០២	១.៣៨៩.៦៨៥	៧៤៤.៦៨៩	-	-	៣.៩០៧.១៨៨
សមមូលជាពាន់រៀល (កំណត់សម្គាល់លេខ ៣.២)	៦.៩៥២.៤២៩	៣៤៦.២៤៦	៥.៧២១.៣៣១	៣.០៦៥.៨៨៣	-	-	១៦.០៨៥.៨៨៩

** មិនរាប់បញ្ចូលចំណាយបង់មុន*

***មិនរាប់បញ្ចូលពន្ធកាត់ទុក និងពន្ធត្រូវបង់ផ្សេងៗ*

ឃ. ការគ្រប់គ្រងដើមទុន

១. ដើមទុនតាមបទប្បញ្ញត្តិ

និយ័តករបស់ក្រុមហ៊ុន គឺធនាគារជាតិនៃកម្ពុជា ដែលជាអ្នកកំណត់ និងតាមដានតម្រូវការដើមទុនសម្រាប់ក្រុមហ៊ុនទាំងមូល។

គោលនយោបាយរបស់ក្រុមហ៊ុន គឺរក្សាបាននូវមូលដ្ឋានដើមទុនដ៏រឹងមាំក្នុងការរក្សាទំនុកចិត្តលើទីផ្សារ និងនិរន្តរភាពនៃការអភិវឌ្ឍអាជីវកម្មបន្ថែមទៀត។ ផលប៉ះពាល់នៃកម្រិតដើមទុនលើផលចំណេញរបស់ភាគហ៊ុនិកក៏ត្រូវបានទទួលស្គាល់ផងដែរ ហើយក្រុមហ៊ុនបានទទួលស្គាល់ពីតម្រូវការដើម្បីរក្សាតុល្យភាពរវាងប្រាក់ចំណេញដែលខ្ពស់ជាងនេះ ដែលអាចធ្វើទៅបានជាមួយនឹងការបង្កើន និងផ្តល់អត្ថប្រយោជន៍ឱ្យកាន់តែច្រើនតាមរយៈស្ថានភាពដើមទុនដ៏សមស្របមួយ។

ក្រុមហ៊ុនបានអនុលោមតាមតម្រូវការដើមទុនដែលបានកំណត់ពីខាងក្រៅទាំងអស់ពេញមួយការិយបរិច្ឆេទ។

២. ការបែងចែកដើមទុន

ការបែងចែកមូលធនរវាងប្រតិបត្តិការជាក់លាក់ និងសកម្មភាពដែលមានទំហំធំធេង ដែលជំរុញដល់ការបង្កើនប្រសិទ្ធភាពនៃផលចំណេញដែលសម្រេចបានលើដើមទុនដែលបានបែងចែក។ សមតុល្យនៃដើមទុនដែលបានបែងចែកទៅតាមប្រតិបត្តិការ ឬសកម្មភាពនីមួយៗ គឺផ្អែកលើដើមទុនតាមបទប្បញ្ញត្តិ។

២៣. ព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍

ពុំមានការកែតម្រូវ ឬព្រឹត្តិការណ៍សំខាន់ៗមិនបានកែតម្រូវណាមួយបានកើតឡើងនៅចន្លោះរវាងកាលបរិច្ឆេទនៃការរាយការណ៍ និងកាលបរិច្ឆេទនៃការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

២៤. ការអនុម័តទៅលើរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដែលបានអនុម័តឱ្យចេញផ្សាយដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤។

អគារលេខ: ២១-២៣-២៥, សង្កាត់ភ្នំពេញថ្មី, ខណ្ឌសែនសុខ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: ០៨៦ ៦៥៥ ៩៩៩, អ៊ីមែល: info@niron.com.kh, វេបសាយ: www.niron.com.kh
Head Office: #21-23-25, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia.
Tel: 086 655 999, Website: www.niron.com.kh, E-mail: info@niron.com.kh, Website: www.niron.com.kh